# កម្មវិធីបរិវត្តកម្មឌីជីថលសហគ្រាស

## ENTERPRISES GO DIGITAL PROGRAM



រៀបចំដោយ

គណៈកម្មាធិការសេដ្ឋកិច្ច និង ធុរកិច្ចឌីជីថល

២០២៣

**អគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការសេដ្ឋកិច្ច និងធុរកិច្ចឌីជីថល**
**រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា**
គេហទំព័រ៖ digitaleconomy.gov.kh

**ឆ្នាំបោះពុម្ពផ្សាយ ៖ ២០២៣**
© អគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការសេដ្ឋកិច្ច និងធុរកិច្ចឌីជីថល (គ.ស.ធ.ឌ) ២០២៣
**អាសយដ្ឋានអគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការសេដ្ឋកិច្ច និងធុរកិច្ចឌីជីថល៖**
អគារមជ្ឈមណ្ឌលអភិវឌ្ឍធុរកិច្ច (BDC), ជាន់ទី១៧, មហាវិថី OCIC, សង្កាត់ជ្រោយចង្វារ,
ខណ្ឌជ្រោយចង្វារ, រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

# អារម្ភកថា

# អារម្ភកថា

កម្ពុជាក៏ដូចជាប្រទេសនៅលើសកលលោក គឺជាប្រទេសដែលមានសេដ្ឋកិច្ចបើកចំហខ្ពស់ និងផ្សារភ្ជាប់កាន់តែខ្លាំងជាមួយនិន្នាការសេដ្ឋកិច្ចតំបន់ និងសកលដែលអាចនឹងបន្តជួបប្រទះនឹងបញ្ហាប្រឈមស្មុគស្មាញ ក៏ដូចជាភាពមិនប្រាកដប្រជាមួយចំនួនពីកត្តាខាងក្រៅ ដែលការណ៍នេះតម្រូវឱ្យរាជរដ្ឋាភិបាលត្រូវបន្តខិតខំបង្កើនប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាពនៃការអនុវត្តវិធានការដែលបានដាក់ចេញ, លើកកម្ពស់ផលិតភាពតាមរយៈការជំរុញសកម្មភាពផលិតកម្មក្នុងស្រុកឱ្យកាន់តែមានសន្ទុះរីកចម្រើនខ្លាំងក្លា, ពង្រឹងពិពិធកម្មសេដ្ឋកិច្ច, និងបង្កើនការយកចិត្តទុកដាក់ខ្ពស់ក្នុងការកសាងភាពធន់ និងការសម្របខ្លួនឱ្យបានឆាប់រហ័សឆ្លើយតបទៅនឹងវិបត្តិដែលបាន និងកំពុងកើតឡើងជាបន្តបន្ទាប់ដូចជាវិបត្តិនៃជំងឺកូវីដ-១៩, ការប្រែប្រួលអាកាសធាតុនិងការផ្លាស់ប្តូរនិម្មាបនកម្មសេដ្ឋកិច្ច និងពាណិជ្ជកម្មសកលក្នុងចំណោមអង្គភាពសេដ្ឋកិច្ចទាំងអស់ ដើម្បីចាប់យកនូវកាលានុវត្តភាពថ្មីៗដែលលេចឡើងក្រោមឥទ្ធិពលនៃវិបត្តិ និងជាពិសេសលើកកម្ពស់សមត្ថភាពប្រកួតប្រជែងរបស់សហគ្រាសកម្ពុជាស្របតាមនិន្នាការតំបន់ និងសកល ដែលឌីជីថលូបនីយកម្ម និងបរិវត្តកម្មឌីជីថលនឹងក្លាយជាកត្តាចម្បងមួយដែលកំណត់ភាពប្រកួតប្រជែងនៅក្នុងទីផ្សារអន្តរជាតិនិងកំណត់ភាពជោគជ័យនៃការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចនៃប្រទេសនីមួយៗនាពេលអនាគត។

ស្ថិតក្នុងយុគសម័យឌីជីថល,បច្ចេកវិទ្យាឌីជីថលបានក្លាយជាផ្នែកមួយនៃជីវិតរស់នៅប្រចាំថ្ងៃ និងមានសក្តានុពលខ្ពស់ក្នុងការចូលរួមចំណែកគាំទ្រ និងជំរុញការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច ហើយបទពិសោធន៍ និងផលវិបាកដែលសេសសល់ក្រោយវិបត្តិកូវីដ-១៩ បានបញ្ជាក់ឱ្យឃើញកាន់តែច្បាស់ពីសារៈសំខាន់នៃបច្ចេកវិទ្យាឌីជីថលដែលបានកែប្រែរបៀបរបបនៃការរស់នៅ, ការបំពេញការងារ, សកម្មភាពអាជីវកម្ម, ប្រតិបត្តិការធុរកិច្ច និងទំនាក់ទំនងពាណិជ្ជកម្ម ដែលរាជរដ្ឋាភិបាលត្រូវបន្តយកចិត្តទុកដាក់ ជាពិសេសទៅលើសមត្ថភាពឌីជីថលរបស់សហគ្រាសគ្រប់កម្រិត និងគ្រប់វិស័យដែលត្រូវបានកំណត់ជាចន្ទល់នៃកំណើនសេដ្ឋកិច្ចរយៈពេលវែង, រួមចំណែកជាងពាក់កណ្តាលនៃផលិតផលក្នុងស្រុកសរុប ព្រមទាំងបានផ្តល់ការងារលើសលុបនៃការងារទាំងអស់។

ដោយពិនិត្យឃើញនូវផលប្រយោជន៍នៃសេដ្ឋកិច្ចឌីជីថល និងតួនាទីនៃបច្ចេកវិទ្យាឌីជីថលក្នុងការបង្កើនផលិតភាព, ជំរុញពិពិធកម្មសេដ្ឋកិច្ច, បង្កើតការងារ និងលើកកម្ពស់វឌ្ឍនភាពនៃសុខាមាលភាពសង្គមឱ្យកាន់តែរីកចម្រើនថែមទៀត, រាជរដ្ឋាភិបាលកម្ពុជាតាមរយៈ **គណៈកម្មាធិការសេដ្ឋកិច្ច និង ធុរកិច្ចឌីជីថល** នឹងដាក់ចេញនូវ **«កម្មវិធីបរិវត្តកម្មឌីជីថលសហគ្រាស»** ក្នុងគោលបំណងពង្រឹងសមត្ថភាពឌីជីថលរបស់សហគ្រាសតាមរយៈការធ្វើបរិវត្តកម្មឌីជីថលសហគ្រាសដើម្បីជំរុញឱ្យសហគ្រាសគ្រប់កម្រិតអាចក្លាយជាភ្នាក់ងារដ៏សកម្មនៅក្នុងសេដ្ឋកិច្ច និង ធុរកិច្ចឌីជីថល។ ដើម្បីសម្រេចគោលបំណងនេះ, គ្រប់ភាគីពាក់ព័ន្ធនៃស្ថាប័នរាជរដ្ឋាភិបាលត្រូវចូលរួមសហការក្នុងការរៀបចំនូវក្របខណ្ឌច្បាប់, លិខិតបទដ្ឋានគតិយុត្ត និងយន្តការគាំទ្រនានាក្នុងន័យបង្កភាពងាយស្រួល, បង្កើតបរិយាកាសអំណោយផលដល់ការធ្វើអាជីវកម្ម និងវិនិយោគដល់បណ្តាវិនិយោគិន និងធុរជន ដែលជាគ្រឹះសំខាន់ក្នុងការជំរុញការចាប់យកបច្ចេកវិទ្យាឌីជីថលប្រកបដោយទំនុកចិត្ត និងភាពជឿជាក់លើបច្ចេកវិទ្យាឌីជីថល។ ចំពោះវិស័យឯកជន ជាពិសេសសហគ្រាសត្រូវចូលរួមប្រើប្រាស់បច្ចេកវិទ្យាឌីជីថលដើម្បីលើកកម្ពស់ប្រសិទ្ធភាព និង ស័ក្តិសិទ្ធិភាពនៃប្រតិបត្តិការអាជីវកម្មប្រកបដោយ

ចីរភាព, បង្កើនផលិតភាព និងពង្រីកទីផ្សារតាមរយៈការថ្លក់ជាមួយខ្សែច្រវាក់ឌីជីថលក្នុងស្រុក, តំបន់ និងសកល និងត្រូវធ្វើនវានុវត្តន៍លើប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានរបស់ខ្លួនជាប្រចាំ និងចូលរួមធ្វើអន្តរប្រតិបត្តិការជាមួយនឹងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានបើកចំហរបស់រាជរដ្ឋាភិបាលដើម្បីផ្តល់សេវាឌីជីថលសំបូរបែបគ្រប់ពេលវេលា និងគ្រប់ទីកន្លែង។ ចំណែកយុវជនត្រូវខិតខំរៀនសូត្របន្ថែមទៅលើជំនាញឌីជីថល និងជំនាញពាក់ព័ន្ធដើម្បីកសាងសង្គម-សេដ្ឋកិច្ចឌីជីថលពោរពេញដោយកម្លាំងពលកម្មដែលមានទេពកោសល្យឌីជីថលច្បាស់លាស់សម្រាប់សេដ្ឋកិច្ច និង ធុរកិច្ចឌីជីថលកម្ពុជា។ ក្នុងន័យនេះ, យន្តការស្ថាប័នក្នុងការសម្របសម្រួលអនុវត្តកម្មវិធីបរិវត្តកម្មឌីជីថលសហគ្រាសក្នុងចំណោមស្ថាប័នរាជរដ្ឋាភិបាល និងកិច្ចសហការមិនអាចខ្វះបានរវាងវិស័យសាធារណៈ និងវិស័យឯកជន ក្នុងការបង្កើនសហថាមពល និងសហបង្កើតថ្មីគឺជាកត្តាកំណត់ភាពជោគជ័យនៃការអនុវត្តកម្មវិធីបរិវត្តកម្មឌីជីថលសហគ្រាសនេះ។

ក្នុងនាមជាប្រធានគណៈកម្មាធិការសេដ្ឋកិច្ច និងធុរកិច្ចឌីជីថល, ខ្ញុំសូមសម្តែងនូវកតញ្ញូតាធម៌ និងកតវេទិតាធម៌យ៉ាងជ្រាលជ្រៅបំផុតជូនចំពោះ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ដែលតែងតែផ្តោតការយកចិត្តទុកដាក់, ផ្តល់អនុសាសន៍ និងការតម្រង់ទិសដ៏ខ្ពង់ខ្ពស់បំផុតទាំងក្នុងក្របខណ្ឌនៃការងារកែទម្រង់ធំៗ និងក្របខណ្ឌនៃការកសាង និងការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមឌីជីថលនៅកម្ពុជា។

ជាទីបញ្ចប់, ខ្ញុំសូមថ្លែងអំណរគុណ និងវាយតម្លៃខ្ពស់ចំពោះថ្នាក់ដឹកនាំ និងមន្ត្រីជំនាញនៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការសេដ្ឋកិច្ច និង ធុរកិច្ចឌីជីថលដែលបានខិតខំរៀបចំឯកសារនៃកម្មវិធីបរិវត្តកម្មឌីជីថលសហគ្រាសនេះរហូតបញ្ចប់ជាស្ថាពរ និងសូមលើកទឹកចិត្តដល់ក្រសួង-ស្ថាប័នពាក់ព័ន្ធ ចូលរួមអនុវត្តតាមសកម្មភាពដែលបានកំណត់នៅក្នុងកម្មវិធីនេះក្នុងស្មារតីនៃកិច្ចសហការ និងការទទួលខុសត្រូវខ្ពស់ និងចូលរួមធ្វើបច្ចុប្បន្នភាពឯកសាររស់មួយនេះក្នុងករណីចាំបាច់ដើម្បីឱ្យស្របតាមការវិវត្តឥតឈប់ឈរនៃបច្ចេកវិទ្យាឌីជីថល និងបទពិសោធន៍នៃការអនុវត្តជាក់ស្តែង។

ថ្ងៃ សុក្រ ២កើត ខែ ពិសាខ ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែមេសា ឆ្នាំ២០២៣

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**
**និងជាប្រធានគណៈកម្មាធិការសេដ្ឋកិច្ច និង ធុរកិច្ចឌីជីថល**

អគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន**

# មាតិកា


លេខទំព័រ

អារម្ភកថា

បញ្ជីរូបភាព និង តារាង ០១

បញ្ជីពាក្យកាត់ ០៣

ខ្លឹមសារសង្ខេបប្រតិបត្តិ ០៤

១ សេចក្តីផ្តើម ០៦

១.១.បរិការណ៍សំខាន់ៗនៃមូលដ្ឋានសេដ្ឋកិច្ចឌីជីថលកម្ពុជា ០៦

១.២.ភាពចាំបាច់នៃកម្មវិធីបរិវត្តកម្មឌីជីថលសហគ្រាស (Enterprises Go Digital) ០៨

២ ទិដ្ឋភាពទូទៅនៃសហគ្រាសនៅកម្ពុជា ១០

២.១.ស្ថានភាពបច្ចុប្បន្ន ១០

២.១.១.និយមន័យ ១០

២.១.២.ទិដ្ឋភាពនៃការចុះបញ្ជីអាជីវកម្មតាមថ្នាលបច្ចេកវិទ្យាព័ត៌មាន ១១

២.១.៣.ទិដ្ឋភាពនៃប្រព័ន្ធអេកូឡូស៊ីសហគ្រាស ១៥

២.១.៤.ទិដ្ឋភាពនៃការប្រើប្រាស់បច្ចេកវិទ្យារបស់សហគ្រាស ២២

២.២.បញ្ហាប្រឈម ២៣

៣ អំពីកម្មវិធីបរិវត្តកម្មឌីជីថលសហគ្រាស ២៧

៣.១.គោលបំណង ២៧

៣.២.គោលដៅ ២៨

៣.៣.សកម្មភាពអាទិភាព ២៨

៣.៣.១.ការលើកកម្ពស់ឌីជីថលូបនីយកម្មនៃប្រតិបត្តិការធុរកិច្ច និងយុទ្ធសាស្ត្រទីផ្សាររបស់សហគ្រាស (General Business and Marketing Functions) ២៩

៣.៣.២.ការស្រាវជ្រាវ និងរៀបចំផែនការបរិវត្តកម្មឌីជីថលសហគ្រាសតាមវិស័យ ៣២

៣.៣.៣.ការអភិវឌ្ឍថ្នាលបរិវត្តកម្មឌីជីថលសហគ្រាស(Enterprises Go Digital Platform) ៣៣

៣.៣.៤.ការបង្កើតមជ្ឈមណ្ឌលបរិវត្តកម្មឌីជីថលសហគ្រាស ៣៤

៣.៣.៥.ការរៀបចំយុទ្ធនាការថ្នាក់ជាតិលើការផ្សព្វផ្សាយ និងការបង្កើនការយល់ដឹង ៣៤

៣.៤.ឃ្នាស់ (Enablers)នៃការអនុវត្តកម្មវិធី ៣៦

៣.៤.១.ក្របខណ្ឌគតិយុត្ត និងយន្តការគាំទ្រពីភាគីពាក់ព័ន្ធ ៣៦

៣.៤.២.ហេដ្ឋារចនាសម្ព័ន្ធឌីជីថល ៣៨

៣.៤.៣.ទេពកោសល្យសម្រាប់សេដ្ឋកិច្ចឌីជីថល ៤១

៣.៥.វិសាលភាព ៤២

៣.៦.ចីរភាពនៃកម្មវិធី ៤២

## ៤ យន្តការដឹកនាំ សម្របសម្រួល និង អនុវត្តកម្មវិធី ៤៣

៤.១.ស្ថាប័នដឹកនាំ សម្របសម្រួល និង អនុវត្តកម្មវិធី ៤៣
៤.២.ការត្រួតពិនិត្យតាមដាន និងការវាយតម្លៃ ៤៣

## ៥ ការបញ្ជ្រាបយេនឌ័រ ៤៦

## ៦ ការគ្រប់គ្រងហានិភ័យ ៤៧

## ៧ សេចក្តីសន្និដ្ឋាន ៤៨

# បញ្ជីរូបភាព និងតារាង

## បញ្ជីរូបភាព និង តារាង


| រូបភាព | ទំព័រ |
|---|---|
| **រូបភាពទី១៖** វិស័យសំខាន់ៗ ក្នុងសេដ្ឋកិច្ចឌីជីថលនៅក្នុងតំបន់ និងកម្ពុជា | ០៦ |
| **រូបភាពទី២៖** ធុរកិច្ចឌីជីថលមួយចំនួនតាមវិស័យក្នុងសេដ្ឋកិច្ចឌីជីថលកម្ពុជា | ០៧ |
| **រូបភាពទី៣៖** និយមន័យសហគ្រាសធុនតូច និងមធ្យមក្នុងប្រទេសកម្ពុជា | ១១ |
| **រូបភាពទី៤៖** ទិន្នន័យក្រុមហ៊ុនដែលបានចុះបញ្ជី និង ចំនួនម្ចាស់ក្រុមហ៊ុន/សហគ្រាស ដែលបានចុះបញ្ជីជាស្ត្រី | ១២ |
| **រូបភាពទី៥៖** សកម្មភាពអាជីវកម្មទាំង៥ ដែលមានដើមទុនចុះបញ្ជីធំជាងគេ | ១៣ |
| **រូបភាពទី៦៖** ដំណាក់កាលទី២ នៃចំនួនក្រុមហ៊ុន/សហគ្រាសស្នើសុំអាជ្ញាបណ្ណជំនាញ | ១៤ |
| **រូបភាពទី៧៖** តួអង្គក្នុងប្រព័ន្ធអេកូឡូស៊ីធុរកិច្ចថ្មី | ១៥ |
| **រូបភាពទី៨៖** ស្ថានភាពនៃប្រព័ន្ធអេកូឡូស៊ីធុរកិច្ចថ្មី | ១៨ |
| **រូបភាពទី៩៖** ប្រព័ន្ធអេកូឡូស៊ីបច្ចេកវិទ្យាហិរញ្ញវត្ថុ | ១៩ |
| **រូបភាពទី១០៖** ទំហំនៃបច្ចេកវិទ្យាហិរញ្ញវត្ថុនៅកម្ពុជា | ២០ |
| **រូបភាពទី១១៖** ទំហំពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកកម្ពុជា | ២១ |
| **រូបភាពទី១២៖** ទិដ្ឋភាពនៃការប្រើប្រាស់បច្ចេកវិទ្យារបស់សហគ្រាស | ២២ |
| **រូបភាពទី១៣៖** ក្របខណ្ឌរួមនៃការអនុវត្តកម្មវិធីបរិវត្តកម្មឌីជីថលសហគ្រាស | ២៧ |
| **រូបភាពទី១៤៖** ទំនាក់ទំនងសកម្មភាពទាំង៥នៃកម្មវិធីបរិវត្តកម្មឌីជីថលសហគ្រាស | ២៨ |
| **រូបភាពទី១៥៖** ការប្រើប្រាស់ផលិតផល/សេវាកម្មឌីជីថលទៅតាមកម្រិត | ៣០ |
| **រូបភាពទី១៦ ៖** ការរៀបចំផែនទីចង្អុលផ្លូវស្តីពីដំណោះស្រាយឌីជីថលទៅតាម ដំណាក់កាលនៃកំណើន | ៣១ |
| **រូបភាពទី១៧៖** ពីរ៉ាមីតនៃការគាំទ្រផ្នែកតាមទំហំអាជីវកម្ម និងវិស័យអាទិភាព | ៣៣ |

| | |
|---|---|
| **រូបភាពទី១៨៖** ការផ្តួចផ្តើមក្នុងការគាំទ្ររបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | ៣៧ |
| **រូបភាពទី១៩៖** ទិន្នន័យនៃស្ថានភាពនៃការតភ្ជាប់ឌីជីថលនៅឆ្នាំ ២០២២ | ៣៨ |
| **រូបភាពទី២០៖** សម្រង់នៃប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានមួយចំនួននៅតាមបណ្តាក្រសួង-ស្ថាប័ន | ៤០ |
| **រូបភាពទី២១៖** សម្រង់នៃប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានមួយចំនួននៃវិស័យឯកជន | ៤០ |
| **រូបភាពទី២២៖** ស្ថានភាពអក្ខរកម្មឌីជីថលកម្ពុជា | ៤១ |


| តារាង | ទំព័រ |
|---|---|


| | |
|---|---|
| **តារាងទី១៖** ការវិភាគអំពីភាពខ្លាំង, ភាពខ្សោយ, កាលានុវត្តភាព និងការគំរាមកំហែងនៃអេកូឡូស៊ីសហគ្រិនភាពនៅកម្ពុជា | ១៦ |
| **តារាងទី២៖** ឧទាហរណ៍នៃការរៀបចំផែនការបណ្តុះបណ្តាលបច្ចេកវិទ្យាឌីជីថលក្នុងអនុវិស័យផលិតចំណីអាហារ | ៣២ |
| **តារាងទី៣៖** សង្ខេបអំពីសកម្មភាពជាអាទិភាពនៃកម្មវិធី | ៣៥ |
| **តារាងទី៤៖** ស្ថានភាពនៃប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាននៅតាមក្រសួង-ស្ថាប័ន | ៣៩ |
| **តារាងទី៥៖** ផែនការអនុវត្ត | ៤៣ |
| **តារាងទី៦៖** ក្របខណ្ឌលទ្ធផលរំពឹងទុកនៃកម្មវិធីបរិវត្តកម្មឌីជីថលសហគ្រាស | ៤៤ |

# បញ្ជីពាក្យកាត់

# បញ្ជីពាក្យកាត់

| | | |
|---|---|---|
| EGD | Enterprises Go Digital | បរិវត្តកម្មឌីជីថលសហគ្រាស |
| ICT | Information Communication Technology | ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងគមនាគមន៍ |
| SMEs | Small and Medium-sized Enterprises | សហគ្រាសធុនតូច និងមធ្យម |
| MSMEs | Micro, Small and Medium-sized Enterprises | សហគ្រាសធុនមីក្រូ, តូច និងមធ្យម |
| CamDX | Cambodia Data Exchange | ថ្នាលផ្លាស់ប្តូរទិន្នន័យកម្ពុជា |
| ERIA | Economic Research Institute for ASEAN and East Asia | វិទ្យាស្ថានស្រាវជ្រាវសេដ្ឋកិច្ចសម្រាប់អាស៊ាន និងអាស៊ីបូព៌ា |
| MEF | Ministry of Economy and Finance | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |
| ADB | Asian Development Bank | ធនាគារអភិវឌ្ឍន៍អាស៊ី |
| WB | World Bank | ធនាគារពិភពលោក |
| GIZ | Gesellschaft für Internationale Zusammenarbeit | កិច្ចសហប្រតិបត្តិការអាល្លឺម៉ង់ |
| FASMEC | Federation of Associations for Small and Medium Enterprises of Cambodia | សម្ព័ន្ធសមាគមសហគ្រាសធុនតូច និងមធ្យមកម្ពុជា |
| IFAD | International Fund for Agricultural Development | មូលនិធិអន្តរជាតិសម្រាប់អភិវឌ្ឍន៍កសិកម្ម |
| SAAMBAT | Sustainable Assets for Agriculture Markets, Business and Trade | គម្រោងគាំទ្រនិរន្តរភាពហេដ្ឋារចនាសម្ព័ន្ធជនបទ ដើម្បីទីផ្សារកសិករ និងពាណិជ្ជូបណីយកម្មកសិកម្ម |
| OBR | Online Business Registration | ប្រព័ន្ធចុះបញ្ជីអាជីវកម្មតាមថ្នាលបច្ចេកវិទ្យាព័ត៌មាន |
| ESOs | Entrepreneurial Support Organizations | យន្តការគាំទ្រពីស្ថាប័នគាំទ្រសហគ្រិនភាព |

# ខ្លឹមសារសង្ខេប
# ប្រតិបត្តិ

## ខ្លឹមសារសង្ខេបប្រតិបត្តិ

បដិវត្តន៍ឧស្សាហកម្ម ៤.០ បានធ្វើឱ្យកម្ពុជា និងសកលលោកផ្តោតការយកចិត្តទុកដាក់ខ្ពស់ទៅលើការធ្វើបរិវត្តកម្មឌីជីថលនៅគ្រប់តួអង្គពាក់ព័ន្ធដែលជំរុញដល់ការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមតាមរយៈការប្រើប្រាស់បច្ចេកវិទ្យាឌីជីថល ជាស្នូលនៃការបំពេញការងារដើម្បីពង្រឹងសមត្ថភាពនៃភាពធន់រឹងមាំ, ឆ្លើយតបទាន់ពេលវេលាទៅនឹងវិបត្តិ, ជំងឺថ្មីៗ និងគ្រោះមហន្តរាយនានាដែលអាចប៉ះពាល់ដល់ជីវភាពរស់នៅប្រចាំថ្ងៃរបស់មនុស្សជាតិ។ ដោយពិនិត្យឃើញនូវសក្តានុពលខ្ពស់នៃបរិវត្តកម្មឌីជីថលដែលមិនអាចប៉ាន់ស្មានបាន, រាជរដ្ឋាភិបាលកម្ពុជាបានដាក់ឱ្យអនុវត្ត **"ក្របខណ្ឌគោល-នយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជា ២០២១-២០៣៥"** ដែលមានចក្ខុវិស័យកសាង និង អភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គមឌីជីថលរស់រវើកនៅកម្ពុជា។ លើសពីនេះទៀត, រាជរដ្ឋាភិបាល ក៏បានដាក់ចេញ **«ក្របខណ្ឌយុទ្ធសាស្ត្រ និងកម្មវិធីស្តារ និងជំរុញកំណើនសេដ្ឋកិច្ចកម្ពុជាក្នុងការរស់នៅជាមួយកូវីដ-១៩តាមគន្លងប្រក្រតីភាពថ្មីឆ្នាំ២០២១-២០២៣»**ដើម្បីពង្រឹងសក្តានុពលនៃចន្ទល់កំណើនសេដ្ឋកិច្ចឱ្យរស់ឡើងវិញ និងចាប់យកនូវកាលានុវត្តភាពថ្មីដើម្បីលើកកម្ពស់ចីរភាពកំណើននិងកសាងភាពធន់នៃសង្គម-សេដ្ឋកិច្ចស្របនឹងនិន្នាការសកលនិងតំបន់ដែលបង្កឡើងដោយវិបត្តិនៃជំងឺកូវីដ-១៩។ បទពិសោធន៍និងស្លាកស្នាមដែលបន្សល់ទុកក្រោយវិបត្តិកូវីដ-១៩ បានបញ្ជាក់ឱ្យឃើញកាន់តែច្បាស់នូវសារៈសំខាន់នៃបច្ចេកវិទ្យាឌីជីថលដែលបានកែប្រែរបៀបរបបនៃការរស់នៅ, ការបំពេញការងារ, សកម្មភាពអាជីវកម្ម និង ប្រតិបត្តិការធុរកិច្ច ដែលរាជរដ្ឋាភិបាលត្រូវបន្តយកចិត្តទុកដាក់ជាពិសេសទៅលើសហគ្រាសជារួម និងសហគ្រាសធុនតូច និងមធ្យមជាពិសេសដែលត្រូវបានកំណត់ថាជាចន្ទល់ និងខ្សែលនៃកំណើនសេដ្ឋកិច្ចរយៈពេលវែងដែលមានប្រមាណ៩៨%នៃធុរកិច្ចទាំងអស់។

សហគ្រាសកម្ពុជារួមទាំងធុរកិច្ចថ្មី និងប្រព័ន្ធអេកូឡូស៊ីធុរកិច្ចឌីជីថល ស្ថិតនៅដំណាក់កាលដំបូងក្នុងការចាប់យក និងការប្រើប្រាស់បច្ចេកវិទ្យាឌីជីថលស្ទើរគ្រប់វិស័យ ហើយក៏មានការចូលរួមតិចតួចក្នុងខ្សែច្រវាក់តម្លៃឌីជីថលទាំងនៅក្នុងតំបន់និងសកល ដែលការណ៍នេះតម្រូវឱ្យរាជរដ្ឋាភិបាលត្រូវបង្កើនល្បឿនបរិវត្តកម្មឌីជីថលសហគ្រាសដើម្បីជំរុញការចាប់យកឌីជីថលសហគ្រាសគ្រប់កម្រិតនិងគ្រប់វិស័យក្នុងន័យពង្រីកទីផ្សារ, ពង្រឹងប្រសិទ្ធភាពប្រតិបត្តិការ, ធានាបាននូវចីរភាពនៃអាជីវកម្ម, បង្កើនផលិតភាព និងប្រសិទ្ធភាព និងលើកកម្ពស់ភាពប្រកួតប្រជែង, ជំរុញការចូលរួមរបស់ក្រុមហ៊ុនឯកជនតាមខ្សែច្រវាក់ឌីជីថលតំបន់ និងសកល, និងជំរុញការបង្កើតធុរកិច្ចថ្មីៗ និងត្រូវយល់ច្បាស់ពីបញ្ហាប្រឈមនានារបស់សហគ្រាស មុននឹងអាចដាក់ចេញនូវវិធានការគោលនយោបាយមុតស្រួចនិងចំទិសដៅ។

**កម្មវិធីបរិវត្តកម្មឌីជីថលសហគ្រាស** ដែលបានរៀបចំឡើងបានគូសរំលេចនូវបញ្ហាប្រឈមធំៗ ចំនួន៦ ដែលសហគ្រាសគ្រប់កម្រិតនៅកម្ពុជាកំពុងជួបប្រទះ ក្នុងការចាប់យកបច្ចេកវិទ្យាឌីជីថលក្នុងនោះរួមមាន ១) ចំណេះដឹង និងការយល់ដឹងពីបច្ចេកវិទ្យាឌីជីថល ២) ការគ្រប់គ្រងប្រតិបត្តិការ, ការថែទាំ និងការអភិវឌ្ឍបច្ចេកវិទ្យាឌីជីថល ៣) ភាពស្ទាក់ស្ទើរក្នុងការប្រើប្រាស់បច្ចេកវិទ្យាឌីជីថល ៤) កិច្ចសហប្រតិបត្តិការរវាងរដ្ឋាភិបាល និងវិស័យឯកជនក្នុងការកសាង អភិវឌ្ឍន៍ និងប្រើប្រាស់ថ្នាលឌីជីថល, ៥) យន្តការទំនាក់ទំនងរបស់សហគ្រាស និង ៦) កង្វះទុនវិនិយោគ។

ដូច្នេះ ដើម្បីដោះស្រាយបញ្ហាប្រឈមដូចបានកំណត់ខាងលើ, សកម្មភាពប្រទាក់ក្រឡាចំនួន ៥ ត្រូវបានដាក់ចេញដោយ សកម្មភាពទី១) ការលើកកម្ពស់ឌីជីថលូបនីយកម្មនៃប្រតិបត្តិការធុរកិច្ច និងយុទ្ធសាស្ត្រទីផ្សាររបស់សហគ្រាស ២) ការស្រាវជ្រាវ និងរៀបចំផែនការបរិវត្តកម្មឌីជីថលសហគ្រាសតាមវិស័យដើម្បីផ្តល់ដំណោះស្រាយឌីជីថលសមស្របជូនដល់សហគ្រាស ៣) ការអភិវឌ្ឍថ្នាលបរិវត្ត-កម្មឌីជីថលសហគ្រាស (Enterprises Go Digital Platform) ដើម្បីប្រមូលផ្តុំព័ត៌មាន និងផ្គូរផ្គងរវៀងអ្នកផ្តល់ និងអ្នកត្រូវការដំណោះស្រាយឌីជីថលទៅតាមកម្រិតត្រៀមខ្លួននៅគ្រប់វិស័យ ៤) ការបង្កើតមជ្ឈមណ្ឌលបរិវត្តកម្មឌីជីថលសហគ្រាសដើម្បីផ្តល់ព័ត៌មាន ឬ ប្រឹក្សាយោបល់ និង ៥) ការរៀបចំយុទ្ធនាការថ្នាក់ជាតិលើការផ្សព្វផ្សាយនិងការបង្កើនការយល់ដឹងក្នុងគោលបំណង**"ពង្រឹងសមត្ថភាពឌីជីថលរបស់សហគ្រាស តាមរយៈការធ្វើបរិវត្តកម្មឌីជីថលសហគ្រាសដើម្បីជំរុញឱ្យសហគ្រាសគ្រប់កម្រិតអាចក្លាយជាភ្នាក់ងារដ៏សកម្មនៅក្នុងសេដ្ឋកិច្ច និង ធុរកិច្ចឌីជីថល"** ហើយលទ្ធផលរំពឹងទុកដែលជាគោលដៅនៃការអនុវត្តកម្មវិធីនេះរួមមាន ១).បង្កើនការផ្តល់ផលិតផល /សេវាកម្មឌីជីថលប្រកបដោយគុណភាពតាមវិស័យនៅលើថ្នាលបរិវត្តកម្មឌីជីថលសហគ្រាស ២).លើកកម្ពស់លទ្ធភាពទទួលបានព័ត៌មាន, បង្កើនការយល់ដឹងអំពីបរិវត្តកម្មឌីជីថល និង ការបណ្តុះបណ្តាលដល់សហគ្រាស និង ៣). លើកកម្ពស់ការប្រើប្រាស់ថ្នាលឌីជីថលរបស់រាជរដ្ឋាភិបាល។ មិនខុសពីកម្មវិធីដទៃដែលបញ្ជាក់ពីគោលបំណង និងលទ្ធផលរំពឹងទុកច្បាស់លាស់, កម្មវិធីបរិវត្តកម្មឌីជីថលសហគ្រាសក៏បានគូសរំលេចពីអភិក្រមនៃការអនុវត្តកម្មវិធី, រចនាសម្ព័ន្ធគ្រប់គ្រង, ផែនការដើម្បីធានាការចូលរួមរបស់ភាគីពាក់ព័ន្ធ, ការបញ្ជ្រាបយេនឌ័រ, ការគ្រប់គ្រងហានិភ័យ, ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃកម្មវិធីដែលជាធាតុផ្សំចាំបាច់ក្នុងការរៀបចំកម្មវិធីឱ្យបានគ្រប់ជ្រុងជ្រោយ និងធានាបាននូវការអនុវត្តប្រកបដោយប្រសិទ្ធភាព។

# ១

# សេចក្ដីផ្ដើម

## ១.សេចក្តីផ្តើម

### ១.១. បរិការណ៍សំខាន់ៗនៃមូលដ្ឋានសេដ្ឋកិច្ចឌីជីថលកម្ពុជា

ការកំណត់អំពីនិយមន័យ និងវិសាលភាពគ្របដណ្តប់នៃសេដ្ឋកិច្ចឌីជីថលនៅមិនទាន់មានភាពជាក់លាក់ និងអាចមានភាពខុសគ្នានៅតាមបណ្តាប្រទេសក្នុងតំបន់ និងក្នុងសកល។ ផ្អែកលើក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជា២០២១-២០៣៥,បានផ្តល់និយមន័យនៃ **«សេដ្ឋកិច្ចឌីជីថល»** ជាពីរនិយមន័យដោយក្នុងន័យទូលាយ (Broad Sense) «សេដ្ឋកិច្ចឌីជីថលសំដៅទៅដល់ប្រព័ន្ធទំនាក់ទំនងសេដ្ឋកិច្ច សង្គម និងវប្បធម៌ដែលពឹងផ្អែកលើការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងគមនាគមន៍ (ICT) និង ឌីជីថល» រីឯ ន័យចង្អៀត (Narrow Sense) «សេដ្ឋកិច្ចឌីជីថលគឺជាទីផ្សារដែលពឹងផ្អែកលើបច្ចេកវិទ្យាឌីជីថលក្នុងការសម្រួលដល់ការដោះដូរទំនិញ និង ការផ្តល់សេវាតាមរយៈពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ឬ ម៉្យាងទៀតគឺជាការប្រើប្រាស់បច្ចេកវិទ្យាឌីជីថលផ្អែកលើអ៊ីនធឺណែតនៅក្នុងដំណើរការផលិតកម្ម និង ការដោះដូរទំនិញ និង សេវា»។

វិស័យឈានមុខគេក្នុងសេដ្ឋកិច្ចឌីជីថលនៅក្នុងតំបន់ និង កម្ពុជារួមមាន ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក, ការដឹកជញ្ជូនទំនិញ និងអាហារ, ការទូទាត់សេវាធ្វើដំណើរអនឡាញ, ប្រព័ន្ធផ្សព្វផ្សាយអនឡាញ និងសេវាហិរញ្ញវត្ថុ។ រីឯវិស័យ៤ទៀតកំពុងស្ថិតនៅក្នុងដំណាក់កាលដំបូងនៅឡើយរួមមាន បច្ចេកវិទ្យាសុខាភិបាល, សេវាកម្មសុសវែរ, បច្ចេកវិទ្យាប្លក់ឆេន និងបច្ចេកវិទ្យាអប់រំ។

**រូបភាពទី១៖** វិស័យសំខាន់ៗ ក្នុងសេដ្ឋកិច្ចឌីជីថលនៅក្នុងតំបន់ និងកម្ពុជា




**ប្រភព៖** e-Conomy SEA 2022

**រូបភាពទី២៖** ធុរកិច្ចឌីជីថលមួយចំនួនតាមវិស័យក្នុងសេដ្ឋកិច្ចឌីជីថលកម្ពុជា




តាមរយៈទិន្នន័យខាងលើបានបង្ហាញនូវការផ្លាស់ប្តូររបៀបរបបនៃការបំពេញការងារ និងការរស់នៅរបស់ប្រជាពលរដ្ឋកម្ពុជានៅក្នុងបដិវត្តន៍ឧស្សាហកម្ម៤.០ ដែលបច្ចេកវិទ្យាព័ត៌មាន និងបច្ចេកវិទ្យាឌីជីថលគឺជាផ្នែកមួយនៃជីវិតរស់នៅប្រចាំថ្ងៃ។ក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ចនិងសង្គមឌីជីថលកម្ពុជា២០២១-២០៣៥ ក៏បានគូសបញ្ជាក់ពីសក្តានុពលនៃតភ្ជាប់សហគ្រាសគ្រប់កម្រិតទៅនឹងខ្សែច្រវាក់ផលិតកម្ម និង ខ្សែច្រវាក់តំបន់និងសកលដែលត្រូវបានរំពឹងថានឹងក្លាយជាមូលដ្ឋានដ៏រឹងមាំក្នុងការទ្រទ្រង់កំណើនសេដ្ឋកិច្ចកម្ពុជាហើយក្របខណ្ឌនេះក៏បានបង្ហាញនូវគម្លាតខុសគ្នានៃការចាប់យក និង ប្រើប្រាស់បច្ចេកវិទ្យាឌីជីថល ក៏ដូចជា ICT របស់សហគ្រាសកម្ពុជានៅក្នុងវិស័យកម្មន្តសាល និងវិស័យសេវាកម្ម និងបានបញ្ជាក់ពីការចូលរួមតិចតួចរបស់សហគ្រាសក្នុងខ្សែច្រវាក់តម្លៃឌីជីថលទាំងនៅក្នុងតំបន់និងសកលដោយសារការវិនិយោគលើសេវូបករណ៍អ៊ីនធឺណែត(Internet Server), ការពង្រឹងសុវត្ថិភាពអ៊ីនធឺណែត និង ទិន្នន័យ ព្រមទាំងអត្រាក្រុមហ៊ុនដែលមានគេហទំព័រផ្ទាល់ខ្លួននៅមានកម្រិតនៅឡើយ។ក្នុងន័យនេះ,ការជំរុញបរិវត្តកម្មឌីជីថលសហគ្រាសគឺជាកត្តាចាំបាច់ដែលត្រូវអនុវត្ត។

## ១.២. ភាពចាំបាច់នៃកម្មវិធីបរិវត្តកម្មឌីជីថលសហគ្រាស (Enterprises Go Digital)

សហគ្រាសគ្រប់កម្រិតជាពិសេសសហគ្រាសធុនតូច និង មធ្យម (SMEs) បានដើរតួនាទីយ៉ាងសំខាន់នៅក្នុងសេដ្ឋកិច្ច។ ផ្អែកតាមទិន្នន័យដែលបានបង្ហាញនៅក្នុងក្របខណ្ឌយុទ្ធសាស្ត្រ និងកម្មវិធីស្តារ និងជំរុញកំណើនសេដ្ឋកិច្ចកម្ពុជាក្នុងការរស់នៅជាមួយកូវីដ-១៩ តាមគន្លងប្រក្រតីភាពថ្មី សម្រាប់ឆ្នាំ ២០២១-២០២៣, សហគ្រាសធុនតូច និង មធ្យមត្រូវបានកំណត់ជាចន្ទល់ និង ប្រភពកំណើនសេដ្ឋកិច្ចរយៈពេលវែង និងការបង្កើតការងារសមរម្យដោយ SMEs មានប្រមាណ ៩៨% នៃធុរកិច្ចទាំងអស់ និងបានចូលរួមដល់សេដ្ឋកិច្ចកម្ពុជាប្រមាណ ៥៨% នៃផលិតផលក្នុងស្រុកសរុប (ផសស) ព្រមទាំងបានផ្តល់ការងារប្រមាណ ៧៣% នៃការងារទាំងអស់។ សម្រាប់ចក្ខុវិស័យរយៈពេលវែង កម្មវិធីរៀបចំឡើងដើម្បី

> **« ជំរុញការចាប់យកឌីជីថលរបស់សហគ្រាសគ្រប់កម្រិត និងគ្រប់វិស័យក្នុងន័យពង្រឹងប្រសិទ្ធភាពប្រតិបត្តិការ, ធានាបាននូវចីរភាពនៃអាជីវកម្ម, បង្កើនផលិតភាព, ពង្រីកទីផ្សារ, និងប្រសិទ្ធភាពសេដ្ឋកិច្ច »**

ដែលអាចប្រែក្លាយប្រទេសកម្ពុជាទៅជាប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់ និងចំណូលខ្ពស់ ដូចបានកំណត់ក្នុងចក្ខុវិស័យ ២០៣០ និង ២០៥០។

បន្ថែមលើនេះ, រាជរដ្ឋាភិបាលត្រូវបន្តយកចិត្តទុកដាក់ និងដាក់ចេញនូវកម្មវិធីឬគម្រោងដែលអាចផ្សារភ្ជាប់, បង្កើនសហថាមពល (Synergy) និងសហបង្កើតថ្មី (Co-Creation) រវាងវិស័យសាធារណៈ និង វិស័យឯកជនក្នុងការជំរុញកំណើនសេដ្ឋកិច្ច និងបង្កើនបរិយាកាសអំណោយផលសម្រាប់ការចាប់យកការប្រើប្រាស់បច្ចេកវិទ្យាឌីជីថល និង ICT នៃតួអង្គសំខាន់ៗ។ក្នុងន័យនេះ, ការដាក់ឱ្យអនុវត្តកម្មវិធីបរិវត្តកម្មឌីជីថលសហគ្រាស នេះរំពឹងថានឹងអាច

> **«បង្កើនសហថាមពល និងសហបង្កើតថ្មី រវាងវិស័យសាធារណៈ និង វិស័យឯកជនក្នុងការពង្រឹងភាពធន់នឹងវិបត្តិ, លើកកម្ពស់ភាពប្រកួតប្រជែង និង ជាឃ្នាស់ដ៏សំខាន់ក្នុងការថ្លក់ជាមួយខ្សែច្រវាក់ឌីជីថលក្នុងតំបន់ និង សកល»**

បើពិនិត្យទៅលើទិដ្ឋភាពប្រកួតប្រជែងក្នុងតំបន់, បណ្តាប្រទេសមួយចំនួនរួមមាន ម៉ាឡេស៊ីបានចាប់ផ្តើមអនុវត្តគម្រោងចាប់តាំងពីឆ្នាំ២០១៥ (SMEs Go Global), ប្រទេសឥណ្ឌូនេស៊ីចាប់ផ្តើមតាំងពីឆ្នាំ ២០១៧ (MSMEs Go Online), សាធារណរដ្ឋសិង្ហបុរីចាប់ផ្តើមតាំងពីឆ្នាំ២០១៧ (SMEs Go Digital), ព្រះរាជាណាចក្រថៃបានវិភាជន៍ថវិកាសម្រាប់ការលើកកម្ពស់ការប្រើប្រាស់បច្ចេកវិទ្យាឌីជីថលរបស់សហគ្រាសធុនតូច និងមធ្យម និងការធ្វើវេខូបនីយកម្ម (Digitization) ក្នុងឆ្នាំ២០២១ និងឆ្នាំ២០២២ និងបណ្តាប្រទេសមួយចំនួនទៀតទាំងក្នុងកម្រិតតំបន់ និងសកល។

កម្មវិធីបរិវត្តកម្មឌីជីថលសហគ្រាសនេះគឺជាផ្នែកមួយនៃការអនុវត្តយុទ្ធសាស្រ្តអាទិភាពដែលបានដាក់ចេញនៅក្នុងសសរស្តម្ភ “ធុរកិច្ចឌីជីថល” នៃក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជា ២០២១-២០៣៥។ កម្មវិធីនេះអាចយកទៅប្រើប្រាស់ជា

**«ក្របខណ្ឌរួមសម្រាប់ជំនួយដល់ការរៀបចំ និង អនុវត្តគម្រោងនានាពាក់ព័ន្ធនឹងបរិវត្តកម្មឌីជីថលសហគ្រាសដើម្បីជំរុញការអភិវឌ្ឍវិស័យឌីជីថលនៅកម្ពុជា ដែលជាចន្ទល់កំណើនសេដ្ឋកិច្ចថ្មី និង ជាចលករគាំទ្រ និងលើកស្ទួយវិស័យទ្រទ្រង់សំខាន់ៗនៃប្រព័ន្ធសេដ្ឋកិច្ចជាតិក្នុងរយៈពេលមធ្យម និងវែង»**

ផ្អែកតាមយុទ្ធសាស្រ្តពាណិជ្ជកម្ម តាមប្រព័ន្ធអេឡិចត្រូនិកបានបញ្ជាក់ថា បច្ចុប្បន្នកម្ពុជាពុំទាន់មានក្របខណ្ឌរួមសម្រាប់ការអភិវឌ្ឍសហគ្រាសដែលធ្វើឱ្យយន្តការជំនួយសម្រាប់សហគ្រាសមានភាពឃើតនិងអាចបង្កើនហានិភ័យក្នុងការរៀបចំគោលនយោបាយមិនចំគោលដៅ ហើយការអនុវត្តសកម្មភាពគោលនយោបាយមានលក្ខណៈដាច់ពីគ្នាក្នុងក្រសួង-ស្ថាប័ន។ សហគ្រាសនៅក្នុងវិស័យពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក និងវិស័យបច្ចេកវិទ្យាព័ត៌មានគឺមិនទាន់មានការយល់ដឹង និង គាំទ្រដូចវិស័យកាត់ដេរឬវិស័យផ្សេងទៀតនៅឡើយដែលក្នុងន័យនេះការពង្រឹងក្របខណ្ឌអភិវឌ្ឍន៍សហគ្រាសត្រូវពង្រឹងជាចាំបាច់ដោយសកម្មភាពធុរកិច្ចឌីជីថលនិងសេដ្ឋកិច្ចឌីជីថលមួយចំណែកធំពាក់ព័ន្ធនឹងសហគ្រាស។

# ២

# ទិដ្ឋភាពទូទៅ
# នៃសហគ្រាស
# នៅកម្ពុជា

## ២. ទិដ្ឋភាពទូទៅនៃសហគ្រាសនៅកម្ពុជា

### ២.១. ស្ថានភាពបច្ចុប្បន្ន

#### ២.១.១. និយមន័យ

ការផ្តល់និយមន័យនៃសហគ្រាសជាពិសេសសហគ្រាសធុនតូចនិងមធ្យមមានលក្ខណៈខុសៗគ្នាទៅតាមបរិបទប្រទេស និង តំបន់ផ្អែកលើចំនួនបុគ្គលិក និង ទំហំទឹកប្រាក់នៃប្រតិបត្តិការប្រចាំឆ្នាំ។ សម្រាប់កម្ពុជា, ការផ្តល់និយមន័យ ឬ លក្ខខណ្ឌវិនិច្ឆ័យសម្រាប់សហគ្រាសនៅក្នុងស្ថាប័នសំខាន់ៗក្នុងវិស័យសាធារណៈរួមមានក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និង នវានុវត្តន៍, អគ្គនាយកដ្ឋានពន្ធដារ និងក្រសួងពាណិជ្ជកម្មពុំទាន់ទទួលស្គាល់ជារួមនៅឡើយ ដោយការផ្តល់និយមន័យ ឬ លក្ខខណ្ឌវិនិច្ឆ័យផ្សេងៗគ្នា។ អគ្គនាយកដ្ឋានពន្ធដារបានប្រើលក្ខខណ្ឌវិនិច្ឆ័យផ្អែកលើបុគ្គលិក និង ចំណូលសម្រាប់គោលបំណងនៃការប្រមូលពន្ធ។ ផ្អែកតាមនិយមន័យដែលកំណត់ក្នុងប្រការ៤ នៃប្រកាសលេខ១៥៩ សហវ.ប្រក ចុះថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០២០ ស្តីពីការណែនាំអនុវត្តអនុក្រឹត្យស្តីពីការលើកទឹកចិត្តផ្នែកពន្ធដារសម្រាប់សហគ្រាសធុនតូចនិងមធ្យមក្នុងវិស័យអាទិភាពបានកំណត់ពាក្យ "សហគ្រាសធុនតូច" សំដៅដល់សហគ្រាសអាជីវកម្មគ្រប់ប្រភេទ ដែលមានផលរបរប្រចាំឆ្នាំចាប់ពី២៥០លានរៀល (ប្រហែល ៦ ២៥០០ ដុល្លារអាមេរិក) ដល់ ៧០០លានរៀល ( ប្រហែល ១៧៥ ០០០ ដុល្លារអាមេរិក) ឬ សហគ្រាសដទៃទៀតដែលជាកម្មវត្ថុនៃការចុះបញ្ជីពន្ធដារជាអ្នកជាប់ពន្ធតូច ស្របតាមច្បាប់និងបទប្បញ្ញត្តិស្តីពីពន្ធដារ ឬ មានចំនួននិយោជិតចាប់ពី ១០នាក់ទៅ៥០ នាក់។"សហគ្រាសធុនមធ្យម"សំដៅដល់សហគ្រាសអាជីវកម្មគ្រប់ប្រភេទដែលមានផលរបរប្រចាំឆ្នាំចាប់ពី ៧០០លានរៀល (ប្រហែល ១៧៥ ០០០ ដុល្លារអាមេរិក) ដល់ ៤ ០០០ លានរៀល ( ប្រហែល ១លានដុល្លារអាមេរិក) ឬ សហគ្រាសដទៃទៀតដែលជាកម្មវត្ថុនៃការចុះបញ្ជីពន្ធដារជាអ្នកជាប់ពន្ធមធ្យមស្របតាមច្បាប់និងបទប្បញ្ញតិស្តីពីពន្ធដារ ឬ មានចំនួននិយោជិតចាប់ពី៥១នាក់ទៅ ១០០នាក់។ និយមន័យនេះគឺប្រើប្រាស់ក្នុងវិសាលភាពនៃការលើកទឹកចិត្តពន្ធដារដូចមានចែងក្នុងប្រកាសខាងលើ និងជានិយមន័យដែលកំណត់នៅក្នុងអនុក្រឹត្យលេខ ១២៤ អនក្រ.បក ចុះថ្ងៃទី ២ ខែ តុលា ឆ្នាំ២០១៨ ស្តីពីការលើកទឹកចិត្តផ្នែកពន្ធដារសម្រាប់សហគ្រាសធុនតូច និង មធ្យមក្នុងវិស័យអាទិភាព។

ដោយឡែក យោងតាមលិខិតលេខ ៣៦ សជណ.ហធ ករណីលទ្ធផលនៃកិច្ចប្រជុំគណៈកម្មធិការសកម្មភាពគោលនយោបាយលើកស្ទួយសហគ្រាសធុនតូច និង មធ្យម (SMEPC) លើកទី២ នៅទីស្តីការគណៈរដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជានាថ្ងៃទី២១ខែមករាឆ្នាំ២០២១សហគ្រាសធុនតូច និងមធ្យមត្រូវបានបែងចែកជា៣វិស័យ និងត្រូវបំពេញតាមលក្ខខណ្ឌដូចខាងក្រោម៖

**រូបភាពទី៣៖** និយមន័យសហគ្រាសធុនតូច និងមធ្យមក្នុងប្រទេសកម្ពុជា

| វិស័យ | ចំនួនបុគ្គលិក | | និង | ផលរបរប្រចាំឆ្នាំ (ដុល្លារអាមេរិក) | | ឬ | ទ្រព្យសកម្ម (ដុល្លារអាមេរិក) | |
|---|---|---|---|---|---|---|---|---|
| | តូច | មធ្យម | | តូច | មធ្យម | | តូច | មធ្យម |
| **កសិកម្ម** | ៥-៤៩ | ៥-១៩៩ | | ៦២,២៥០ - ២៥០,០០០ | ២៥០,០០១ - ១០០,០០០,០០០ | | ៥០,០០០ - ២៥០,០០០ | ២៥០,០០១ - ៥០០,០០០ |
| **ឧស្សាហកម្ម** | ៥-៤៩ | ៥-១៩៩ | | ៦២,៥០០ - ៤០០,០០០ | ៤០០,០០១ - ២០០,០០០,០០០ | | ៥០,០០០ - ៥០០,០០០ | ៥០០,០០១ - ១០០,០០០,០០០ |
| **សេវាកម្ម និង ពាណិជ្ជកម្ម** | ៥-៤៩ | ៥-១៩៩ | | ៦២,៥០០- ២៥០,០០០ | ២៥០,០០១ - ១,៥០០,០០០ | | ៥០,០០០- ២៥០,០០០ | ២៥០,០០១ - ៥០០,០០០ |

**ប្រភព៖** សេចក្តីជូនដំណឹងរបស់រាជរដ្ឋាភិបាលលេខ ៣៦ សជណ.ហធ

និយមន័យដែលមានលក្ខណៈស្តង់ដារមួយគឺជាចំណុចចាប់ផ្តើមយ៉ាងសំខាន់សម្រាប់ការបង្កើតគោលនយោបាយ និងការវាស់វែងទិន្នន័យទាក់ទងនឹងសហគ្រាសនៅកម្ពុជា។ ក្នុងន័យនេះ, និយមន័យដូចមានចែងនៅក្នុងសេចក្តីជូនដំណឹងខាងលើត្រូវបានប្រើប្រាស់ទូលំទូលាយនាពេលបច្ចុប្បន្ន។

## ២.១.២. ទិដ្ឋភាពនៃការចុះបញ្ជីអាជីវកម្មតាមថ្នាលបច្ចេកវិទ្យាព័ត៌មាន

នៅខែធ្នូ ឆ្នាំ២០២២, វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការបានបង្ហាញនូវរបាយការណ៍លទ្ធផលបឋមនៃជំរឿនសេដ្ឋកិច្ចនៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០២២ ដែលរបាយការណ៍លទ្ធផលចុងក្រោយគ្រោងនឹងផ្សព្វផ្សាយនៅខែកក្កដា ឆ្នាំ២០២៣ ដោយលទ្ធផលនៃរបាយការណ៍បឋមបានបង្ហាញនូវអង្គភាពសេដ្ឋកិច្ច[1]សរុបទាំងអស់ចំនួន ៧៥៣ ៦៧០ អង្គភាពសេដ្ឋកិច្ចដោយក្នុងនោះអង្គភាពសេដ្ឋកិច្ចដែលបានចុះបញ្ជីមានចំនួនត្រឹមតែ ៩៣ ៦៤៧ ប្រមាណ ១២,៤% ខណៈដែលអង្គភាពសេដ្ឋកិច្ចមិនបានចុះបញ្ជីមានរហូតដល់ ៦៦០ ០២៣ ប្រមាណ ៨៧,៦%។ ផ្អែកតាមសេចក្តីប្រកាសព័ត៌មានស្តីពីលទ្ធផលកិច្ចប្រជុំ គណៈកម្មាធិការសកម្មភាពគោលនយោបាយលើកស្ទួយសហគ្រាសធុនតូចនិងមធ្យមលើកទី២ កាលពីថ្ងៃទី២៣ ខែ កញ្ញា ឆ្នាំ ២០២០ ដែលអង្គប្រជុំបានពិភាក្សាអំពីការលុបបំបាត់ និងការកែសម្រួលការផ្តល់អាជ្ញាបណ្ណ ឬវិញ្ញាបនបត្រដែលត្រួតគ្នា, អាជ្ញាបណ្ណ ឬវិញ្ញាបនបត្រដែលផ្តល់ត្រួតរវាងក្រសួង-ស្ថាប័នពាក់ព័ន្ធត្រូវលុបបំបាត់និងកែសម្រួលដោយផ្អែកលើអភិក្រមតម្លៃបន្ថែមនិងវិចារណកម្ម (rationalization) និងដោយប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន។ ដើម្បីដោះស្រាយបញ្ហាប្រឈម និងសម្រួលដល់ការងារចុះបញ្ជី, រាជរដ្ឋាភិបាលបានដាក់ឱ្យដំណើរការជាផ្លូវការនូវប្រព័ន្ធចុះបញ្ជីអាជីវកម្មតាមថ្នាលបច្ចេកវិទ្យាព័ត៌មាន (Online Business Registration-OBR) ដែលមាននៅលើថ្នាលផ្លាស់ប្តូរទិន្នន័យកម្ពុជា (CamDX) ដំណាក់កាលទី១ នៅថ្ងៃទី១៥ ខែ មិថុនា ឆ្នាំ ២០២០ ដោយផ្តល់ភាពងាយស្រួលដល់ធុរជនក្នុងការចុះបញ្ជីអាជីវកម្ម, ចំណាយពេលវេលា និងថវិកាតិចជាងមុន និងធ្វើជាកញ្ចប់តាមនីតិវិធីអនឡាញជាមួយក្រសួង-ស្ថាប័នចំនួន៣ រួមមាន **ក្រសួងពាណិជ្ជកម្ម, អគ្គនាយកដ្ឋានពន្ធដារ និង ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ** ។

[1] អង្គភាពសេដ្ឋកិច្ច គឺជាអង្គការអាជីវកម្មមួយឬផ្នែកនៃអង្គភាពអាជីវកម្មដែលស្ថិតនៅទីតាំងជាក់លាក់មួយ និងមានអ្នកគ្រប់គ្រងអាជីវកម្ម ហើយនិងមានសកម្មភាពផលិតតែមួយ (មិនមែនជាសម្ព័ន្ធ) ដែលបានធ្វើសកម្មភាពផលិត ឬ សកម្មភាពផលិតចម្បងដែលមានភាគចំណែកច្រើនលើតម្លៃបន្ថែម។ (ប្រភព៖របាយការណ៍លទ្ធផលបឋមជំរឿនសេដ្ឋកិច្ចនៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០២២, ខែធ្នូ ឆ្នាំ២០២២)

ផ្អែកលើទិន្នន័យស្ថិតិនៃការចុះបញ្ជីអាជីវកម្មតាមថ្នាលបច្ចេកវិទ្យាព័ត៌មាន (CamDX) គិតចាប់ពីថ្ងៃទី១៥ ខែ មិថុនា ឆ្នាំ ២០២០ រហូតដល់ថ្ងៃទី១៦ ខែមករា ឆ្នាំ២០២៣, ក្រុមហ៊ុន/សហគ្រាស ដែលបាន ចុះបញ្ជីជោគជ័យ មានចំនួន ២០ ៩១៥ និងមានសកម្មភាពអាជីវកម្មចម្បងចំនួន៥ ដែលទទួលបានការចុះបញ្ជីអាជីវកម្មច្រើនជាងគេ រួមមាន ការសាងសង់, កម្មន្តសាល, អាហារ័ណនីហារ័ណ ទិញលក់ ជួសជុលយានយន្ត និងទោចក្រយានយន្តគ្រប់ប្រភេទ, សកម្មភាពអចលនវត្ថុ និង សកម្មភាពវិជ្ជាជីវៈ វិទ្យាសាស្ត្រ និងបច្ចេកទេស។ សម្រាប់ចំនួនម្ចាស់ក្រុមហ៊ុន/សហគ្រាសដែលបានចុះបញ្ជីជាស្ត្រីមានចំនួន៣៨% និងបុរសមានចំនួន ៦២%។

**រូបភាពទី៤៖** ទិន្នន័យក្រុមហ៊ុនដែលបានចុះបញ្ជី និង ចំនួនម្ចាស់ក្រុមហ៊ុន/សហគ្រាសដែលបានចុះបញ្ជីជាស្ត្រី

គិតចាប់ពីថ្ងៃទី១៥ ខែមិថុនា ឆ្នាំ ២០២០ រហូតដល់ថ្ងៃទី១៦ ខែមករា ឆ្នាំ២០២៣

ចំនួនក្រុមហ៊ុនចុះបញ្ជីទទួលបានជោគជ័យ

**២០ ៩១៥**

សកម្មភាពអាជីវកម្មចម្បងចំនួន ៥ ដែលទទួលបានការចុះបញ្ជីអាជីវកម្មច្រើនជាងគេ

-ការសាងសង់
-កម្មន្តសាល
-អាហារ័ណនីហារ័ណ ទិញលក់ ជួសជុលយានយន្ត និងទោចក្រយានយន្តគ្រប់ប្រភេទ
-សកម្មភាពអចលនវត្ថុ និង សកម្មភាពវិជ្ជាជីវៈ
-វិទ្យាសាស្ត្រ និងបច្ចេកទេស។

ចំនួនម្ចាស់ក្រុមហ៊ុន/សហគ្រាសដែលបានចុះបញ្ជីជាស្ត្រី




**ប្រភព៖** ប្រព័ន្ធចុះបញ្ជីអាជីវកម្មតាមថ្នាលបច្ចេកវិទ្យាព័ត៌មាន

បន្ថែមលើនេះ, សកម្មភាពអាជីវកម្ម៥ដែលមានដើមទុនវិនិយោគធំជាងគេរួមមាន ១) ការសាងសង់អគារមានចំនួនប្រមាណ ៩៧៧ លានដុល្លារអាមេរិកស្មើនឹង ១៧%, សកម្មភាពអចលនទ្រព្យដោយអចលនទ្រព្យផ្ទាល់ខ្លួន ឬជួលពីគេមានចំនួនប្រមាណ ៧២២ លានដុល្លារអាមេរិកស្មើនឹង ១២%, សកម្មភាពពិគ្រោះយោបល់ផ្នែកគ្រប់គ្រងមានចំនួនប្រមាណ ២៩៧ លានដុល្លារអាមេរិកស្មើនឹង ៥%, កម្មន្តសាលសម្លៀកបំពាក់លើកលែងសម្លៀកបំពាក់ធ្វើពីរោមសត្វមានចំនួនប្រមាណ ២៨២លានដុល្លារអាមេរិកស្មើនឹង ៥%, ការលក់ដុំឯកទេសផ្សេងៗមានចំនួន ២៦០លានដុល្លារអាមេរិកស្មើនឹង ៤% និងផ្សេងៗមានចំនួន ៣,២៩ ប៊ីលានដុល្លារអាមេរិកស្មើនឹង ៥៦%។

**រូបភាពទី៥៖** សកម្មភាពអាជីវកម្មទាំង៥ ដែលមានដើមទុនចុះបញ្ជីធំជាងគេ




**ប្រភព៖** ប្រព័ន្ធចុះបញ្ជីអាជីវកម្មតាមថ្នាលបច្ចេកវិទ្យាព័ត៌មាន

ការដាក់ឱ្យអនុវត្តប្រព័ន្ធចុះបញ្ជីអាជីវកម្មតាមថ្នាលបច្ចេកវិទ្យាព័ត៌មានដំណាក់កាលទី១ បានសម្រួលដល់ការចុះបញ្ជីកាន់តែមានលក្ខណៈល្អប្រសើរ ប៉ុន្តែនៅតែមានបញ្ហាពេលវេលា និងបញ្ហាពាក់ព័ន្ធមួយចំនួនបន្ទាប់ពីការចុះបញ្ជី ដោយសារក្រុមហ៊ុន/សហគ្រាសត្រូវបន្តស្នើសុំ អាជ្ញាបណ្ណ/វិញ្ញាបនបត្រ/លិខិតអនុញ្ញាត/ប្រកាសបង្កើតបន្ថែមទៀត។ ដើម្បីសម្រួលដល់កិច្ចការនេះ, ប្រព័ន្ធចុះបញ្ជីអាជីវកម្មតាមថ្នាលបច្ចេកវិទ្យាព័ត៌មាន ក៏បានពង្រីកវិសាលភាពទៅ ដំណាក់កាលទី២ និងត្រូវបានដាក់ឱ្យអនុវត្តដោយរាជរដ្ឋាភិបាល កាលពីថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០២១ ដែលអនុញ្ញាតឱ្យក្រុមហ៊ុន/សហគ្រាសដាក់ស្នើសុំអាជ្ញាបណ្ណជំនាញតាមអនឡាញសម្រាប់ក្រសួង-ស្ថាប័នចំនួន៤រួមមាន ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និង នវានុវត្តន៍, ក្រសួងទេសចរណ៍, ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍ និងនិយ័តករអាជីវកម្មអចលនវត្ថុនិងបញ្ចាំនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ។ គិតចាប់ពីថ្ងៃដាក់ ដំណើរការមកដល់ថ្ងៃទី១៦ ខែ មករា ឆ្នាំ២០២៣នេះ, ការស្នើសុំប្រកាសបង្កើតសហគ្រាសធុនតូច និង មធ្យមមានតែ ៥ សហគ្រាសប៉ុណ្ណោះ ខណៈដែលការស្នើសុំអាជ្ញាបណ្ណជំនាញពីក្រសួងទេសចរណ៍មានចំនួន ១២៧, ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍មានចំនួន ២២៧ និង និយ័តករអាជីវកម្មអចលនវត្ថុ និងបញ្ចាំនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារមានចំនួន ៦៤។

**រូបភាពទី៦៖** ដំណាក់កាលទី២ នៃចំនួនក្រុមហ៊ុន/សហគ្រាសស្នើសុំអាជ្ញាបណ្ណជំនាញ

*គិតចាប់ពីថ្ងៃទី ០១ ខែកញ្ញា ឆ្នាំ២០២១ ដល់ថ្ងៃទី១៦ ខែមករា ឆ្នាំ២០២៣

| | | |
|---|---|---|
| ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | ០៥ | ជោគជ័យ |
| ក្រសួងទេសចរណ៍ | ១២៧ | ជោគជ័យ |
| ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ | ២២៧ | ជោគជ័យ |
| និយ័តករអាជីវកម្មអចលនវត្ថុនិងបញ្ចាំ នៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ | ៦៤ | ជោគជ័យ |

**ប្រភព៖** ប្រព័ន្ធចុះបញ្ជីអាជីវកម្មតាមថ្នាលបច្ចេកវិទ្យាព័ត៌មាន

បើតាមសេចក្តីប្រកាសព័ត៌មានក្នុងការដាក់ឱ្យអនុវត្តជាផ្លូវការដំណាក់កាលទី២, ការស្នើសុំអាជ្ញាបណ្ណ/វិញ្ញាបនបត្រ/លិខិតអនុញ្ញាត/ប្រកាសបង្កើតតាមរយៈអនឡាញនេះនឹងបន្តពង្រីកវិសាលភាពទៅដំណាក់កាលបន្តបន្ទាប់ទៀតដើម្បីសម្រួលដល់ធុរជនក្នុងការស្នើសុំអាជ្ញាបណ្ណ/វិញ្ញាបនបត្រ/លិខិតអនុញ្ញាត/ប្រកាសបង្កើតទៅតាមប្រភេទអាជីវកម្ម។

### ២.១.៣. ទិដ្ឋភាពនៃប្រព័ន្ធអេកូឡូស៊ីសហគ្រាស

ការអភិវឌ្ឍប្រព័ន្ធអេកូឡូស៊ីសហគ្រាសរួមមានសហគ្រិនភាព និង ធុរកិច្ចថ្មីស្ថិតនៅដំណាក់កាលដំបូងនៅឡើយសម្រាប់កម្ពុជា និងមានកត្តារាំងស្ទះមួយចំនួនរាប់ចាប់ពីកត្តានៃការខ្វះហេដ្ឋារចនាសម្ព័ន្ធឌីជីថលរឹង និងទន់, ក្របខណ្ឌច្បាប់, សមត្ថភាព, ការគាំទ្រផ្នែកហិរញ្ញវត្ថុ និងមិនមែនហិរញ្ញវត្ថុ និងការផ្តល់ប្រឹក្សាយោបល់ ឬការផ្តល់បរិយាកាសអំណោយផលនានា ។ ដើម្បីលើកកម្ពស់នូវលក្ខខណ្ឌអំណោយផលសម្រាប់ប្រព័ន្ធអេកូឡូស៊ីសហគ្រាសនៅក្នុងសេដ្ឋកិច្ចឌីជីថលការគាំទ្រពីវិស័យសាធារណៈ, វិស័យឯកជននិងដៃគូអភិវឌ្ឍន៍គឺជាកត្តាចាំបាច់ហើយយន្តការសម្របសម្រួលស្ថាប័នទាំងនេះក៏ជាកត្តាដែលត្រូវយកចិត្តទុកដាក់ផងដែរ។ ក្នុងឆ្នាំ២០២២, មជ្ឈមណ្ឌលបណ្តុះធុរកិច្ចថ្មី “តេជោ” ក៏បានធ្វើការស្រាវជ្រាវលើប្រព័ន្ធអេឡូស៊ីធុរកិច្ចថ្មីពាក់ព័ន្ធបច្ចេកវិទ្យានៅកម្ពុជា(Tech Startup Ecosystem in Cambodia  2022) ស្តីពីបញ្ហាប្រឈម, កាលានុវត្តភាព និងដំណើរឆ្ពោះទៅមុខដោយនៅក្នុងរបាយការណ៍ស្រាវជ្រាវបានបង្ហាញនូវបញ្ហាប្រឈមដែលធុរកិច្ចថ្មីពាក់ព័ន្ធនឹងបច្ចេកវិទ្យាជួបប្រទះ, យន្តការគាំទ្រពីស្ថាប័នគាំទ្រសហគ្រិនភាព (Entrepreneurial Support Organizations-ESOs) តាមរយៈកម្មវិធី incubator/accelerator, ព្រឹត្តិការណ៍គាំទ្រធុរកិច្ចថ្មី, ការបណ្តុះបណ្តាល និងយន្តការកៀរគរធនធានមួយចំនួនដើម្បីផ្តល់ធនធានគាំទ្រដល់ធុរកិច្ចថ្មីព្រមទាំង សហគ្រាសធុនតូច និងមធ្យមផងដែរ, ការដាក់ចេញនូវលិខិតបទដ្ឋានគតិយុត្តរបស់រាជរដ្ឋាភិបាលដើម្បីផ្តល់លក្ខខណ្ឌអំណោយផលនិងកាលានុវត្តភាពសម្រាប់ធុរកិច្ចថ្មី និងការដាក់ចេញនូវអនុសាសន៍គន្លឹះសំខាន់ៗមួយចំនួនជាជំនួយដល់ធុរកិច្ចថ្មី និងស្ថាប័នគាំទ្រសហគ្រិនភាពផ្អែកតាមលទ្ធផលនៃការស្រាវជ្រាវ។ បន្ថែមលើនេះ, មជ្ឈមណ្ឌលបណ្តុះធុរកិច្ចថ្មី “តេជោ” ក៏បានប្រមូលផ្តុំតួអង្គ សំខាន់ៗនៅក្នុងប្រព័ន្ធអេកូឡូស៊ីធុរកិច្ចថ្មីតាមរយៈថ្នាលធុរកិច្ចថ្មីកម្ពុជា (Startup Cambodia Platform)។

**រូបភាពទី៧៖** តួអង្គក្នុងប្រព័ន្ធអេកូឡូស៊ីធុរកិច្ចថ្មី




**ប្រភព៖** STARTUPCAMBODIA

**តារាងទី១៖** ការវិភាគអំពីភាពខ្លាំង, ភាពខ្សោយ, កាលានុវត្តភាព និងការគំរាមកំហែងនៃអេកូឡូស៊ីសហគ្រិនភាពនៅកម្ពុជា

### ភាពខ្លាំង

- ការរីកដុះដាលនៃវប្បធម៌សហគ្រិនភាព (Entrepreneurial culture)
- សហគ្រាសធុនតូច និងមធ្យមប្រកបដោយជវភាព និងការសម្របខ្លួនខ្ពស់ (Dynamic and Adaptive SMEs)
- ទិដ្ឋភាពនៃការចាប់ផ្ដើមប្រើប្រាស់បច្ចេកវិទ្យាដ៏រស់រវើក
- ការកើនឡើងនូវចំណាប់អារម្មណ៍ពីមូលធនឯកជន និងការបណ្ដាក់ទុនក្នុងស្រុក
- កម្ពុជាស្ថិតនៅទីតាំងប្រកបដោយជវភាព និងរស់រវើកក្នុងតំបន់អាស៊ាន ជាពិសេសនៅចំចន្លោះរវាងប្រទេសថៃ និងវៀតណាម
- គោលនយោបាយសេដ្ឋកិច្ចបើកចំហ ដើម្បីទាក់ទាញការវិនិយោគ ដែលអាចនាំឱ្យមានការផ្ទេរចំណេះដឹង និងជំនាញក្នុងរយៈពេលមធ្យម ទៅរយៈពេលវែង

### ភាពខ្សោយ

- សហគ្រាសដែលមិនទាន់ចុះបញ្ជីមានច្រើន
- កង្វះខាតជំនួយពីរាជរដ្ឋាភិបាល
- លទ្ធភាពទទួលបានហិរញ្ញប្បទាន (access to finance) នៅតែទាមទារនូវទ្រព្យបញ្ចាំ ដូចជា ដីធ្លី ឬអចលនទ្រព្យ និងមានតម្លៃថ្លៃ
- កង្វះសេវាកម្មគាំទ្រធុរកិច្ចប្រកបដោយប្រសិទ្ធភាព
- ត្រូវពង្រឹងសមត្ថភាពសហគ្រិន (ជំនាញផ្នែកហិរញ្ញវត្ថុ, ផែនការអាជីវកម្ម)
- ការពង្រីកទៅកាន់ទីផ្សារខាងក្រៅ (អន្តរជាតូបនីយកម្ម-internationalization)
- កង្វះបុគ្គលិក/អ្នកគ្រប់គ្រងដែលមានសមត្ថភាព
- អភិបាលកិច្ចសាជីវកម្មនៅមានកម្រិត (Week corporate governance)
- សមត្ថភាពក្នុងការបង្កើតឧស្សាហកម្មប្រតិគមន៍នៅមានកម្រិត ( (Inability to create backward linkage)
- ថាមពលអគ្គិសនី និងការដឹកជញ្ជូនមានតម្លៃខ្ពស់ ដែលអាចជះឥទ្ធិពលទៅលើវិស័យកម្មន្តសាល

## កាលានុវត្តភាព

- បរិយាកាសធុរកិច្ចល្អនាំឱ្យមានភាពងាយស្រួលក្នុងការវិនិយោគ
- បង្កើនគំនិតផ្តួចផ្តើមរបស់រដ្ឋាភិបាល និងកម្មវិធីជំនួយសម្រាប់សហគ្រាសធុនតូច និងមធ្យម
- កាលានុវត្តភាពនៃវិស័យ និងទីតាំងភូមិសាស្ត្រ (ខេត្ត) មួយចំនួនដែលមិនទាន់ទាញយកសក្តានុពល (Untapped Sector and geographic (provinces) opportunities)
- ការកែលម្អនូវហេដ្ឋារចនាសម្ព័ន្ធតភ្ជាប់ដូចជា ផ្លូវ ថ្នល់ និងការបង្កើនសមត្ថភាពកំពង់ផែ ដើម្បីកាត់បន្ថយថ្លៃដឹកជញ្ជូន
- កម្មវិធីកំណែទម្រង់ពន្ធគយ ដើម្បីលើកកម្ពស់ការសម្របសម្រួលការធ្វើពាណិជ្ជកម្ម (Trade facilitation)
- បង្កើនសមត្ថភាពផ្គត់ផ្គង់អគ្គិសនី ដើម្បីបញ្ចុះតម្លៃការប្រើប្រាស់អគ្គិសនី
- មានសក្តានុពលក្នុងការប្រើប្រាស់បច្ចេកវិទ្យាថ្មីៗដោយកម្ពុជាមានកម្លាំងពលកម្មវ័យក្មេង ដើម្បីបង្កើនប្រសិទ្ធភាព និងផលិតភាព

## ការគំរាមកំហែង

- កង្វះការសម្របសម្រួលរវាងភាគីពាក់ព័ន្ធ (សូម្បីនៅក្នុងស្ថាប័នរាជរដ្ឋាភិបាល)
- បរិយាកាសអំណោយផលសម្រាប់ធុរកិច្ចនៅមានកម្រិត ( ការទទួលបានព័ត៌មាន, តម្លៃអគ្គិសនី និង ការដឹកជញ្ជូនខ្ពស់)
- ភាពទន់ខ្សោយនៃសេដ្ឋកិច្ច ងាយរងគ្រោះនឹងការប៉ះទង្គិចពីខាងក្រៅ (ផលវិបាកនៃការដក EBA ការធ្លាក់ចុះនៃសេដ្ឋកិច្ចពិភពលោកទាក់ទងនឹងការរីករាលដាលនៃជំងឺកូវីដ-១៩)
- ថ្លៃដើមខ្ពស់ក្នុងការចាប់ផ្តើមអាជីវកម្ម និងការអនុលោមភាពតាមបទប្បញ្ញត្តិធ្វើឱ្យសហគ្រាសធុនតូច និងមធ្យមនៅក្រៅផ្លូវការច្រើន (remain informal)
- ការអនុវត្តកំណែទម្រង់ដើម្បីបង្កើនភាពប្រកួតប្រជែងនៃសហគ្រាសធុនតូច និងមធ្យម និងការថ្នក់ជាមួយខ្សែច្រវ៉ាក់ផលិតកម្មនៅមានកម្រិត
- មានការកើនឡើងនៃនិន្នាការចំណាកស្រុកនៃកម្លាំងពលកម្ម វ័យក្មេងដែលនាំឱ្យការផ្គត់ផ្គង់កម្លាំងពលកម្មក្នុងស្រុកនៅមានកម្រិត

**ប្រភព៖** SME Internationalization in Cambodia: Study on Barriers and Mapping of Supporting Service Providers, ARISE Plus Cambodia and ASEAN SME Projects, 2020.

បន្ថែមលើនេះ មជ្ឈមណ្ឌលបណ្តុះធុរកិច្ចថ្មី “តេជោ” ក៏បានសហការជាមួយ Deep Ecosystem និង Swisscontact ដើម្បីពិនិត្យទៅលើស្ថានភាពនៃប្រព័ន្ធអេកូឡូស៊ីធុរកិច្ចថ្មី និងបានបង្ហាញនូវរបាយការណ៍ក្នុងឆ្នាំ២០២២ដូចមានក្នុងរូបភាពខាងក្រោម។

**រូបភាពទី៨៖** ស្ថានភាពនៃប្រព័ន្ធអេកូឡូស៊ីធុរកិច្ចថ្មី

A data-driven approach to assess the healthiness of Cambodia Startup Ecosystem




ចំពោះប្រព័ន្ធអេកូឡូស៊ីនៅក្នុងវិស័យបច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជា, នៅចុងឆ្នាំ២០១៩ និងដើមឆ្នាំ២០២០, មជ្ឈមណ្ឌលបណ្តុះធុរកិច្ចថ្មី “តេជោ” បានធ្វើការស្រាវជ្រាវមួយដែលទាក់ទងទៅនឹងទិដ្ឋភាពបច្ចេកវិទ្យាហិរញ្ញវត្ថុនៅកម្ពុជាដោយបានរកឃើញនូវបញ្ហាប្រឈមចំនួនបីសម្រាប់ប្រព័ន្ធអេកូ-ឡូស៊ីនៅក្នុងវិស័យបច្ចេកវិទ្យាហិរញ្ញវត្ថុរួមមានកង្វះខាតនូវយន្តការសម្របសម្រួលរវាងស្ថាប័ន,កង្វះខាតក្របខណ្ឌច្បាប់ និង Sandbox សម្រាប់ការសាកល្បងផលិតផល និងសេវា ដែលមានភាពច្នៃប្រឌិតថ្មី និងកង្វះខាតនូវធនធានមនុស្ស។ ដើម្បីពង្រឹងប្រព័ន្ធអេកូឡូស៊ីបច្ចេកវិទ្យាហិរញ្ញវត្ថុ, នៅចុងឆ្នាំ២០២២, កម្ពុជាបានរៀបចំ “វេទិកាបច្ចេកវិទ្យាហិរញ្ញវត្ថុ-FinTech Stage” លើកដំបូងនៅក្នុងព្រឹត្តិការណ៍ពិព័រណ៍បច្ចេកវិទ្យាកម្ពុជា២០២២ (CamTech Summit 2022) ដែលមានការចូលរួមពីថ្នាក់ដឹកនាំក្រសួង-ស្ថាប័ន, គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ, គ្រឹះស្ថានអប់រំ, ស្ថាប័នស្រាវជ្រាវ, ដៃគូអភិវឌ្ឍន៍, សមាគម និងភាគីពាក់ព័ន្ធក្នុងវិស័យឯកជន។

បើតាមសេចក្តីប្រកាសព័ត៌មាន “វេទិកាបច្ចេកវិទ្យាហិរញ្ញវត្ថុ” ត្រូវបានរៀបចំក្នុងគោលបំណងគាំទ្រ និងជំរុញការអភិវឌ្ឍសេដ្ឋកិច្ចឌីជីថល និង បច្ចេកវិទ្យាហិរញ្ញវត្ថុនៅកម្ពុជាដោយកៀរគរនិយ័តករ, វិស័យឯកជន, ស្ថាប័នជាតិ និង អន្តរជាតិពាក់ព័ន្ធដើម្បីរៀនសូត្រពីគ្នាទៅវិញទៅមកនិងស្វែងយល់បន្ថែមឱ្យកាន់តែច្បាស់ពីនិន្នាការ និង នវានុវត្តន៍ឬផលិតផលបច្ចេកវិទ្យាហិរញ្ញវត្ថុ ព្រមទាំងពិភាក្សាពី កាលានុវត្តភាព និងបញ្ហាប្រឈម នានាដើម្បីពង្រឹង និង ពង្រីកប្រព័ន្ធអេកូឡូស៊ីបច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជាក្តោបយកឱកាសជាអតិបរមាពីនវានុវត្តន៍ទាំងនោះ ព្រមទាំងសម្រប និងត្រៀមខ្លួនសម្រាប់ការវិវត្តដ៏រហ័សនៃបច្ចេកវិទ្យាហិរញ្ញវត្ថុនៅកម្ពុជា។ ក្នុងន័យនេះ, កម្ពុជាបាននិងកំពុងកសាងនូវប្រព័ន្ធអេកូឡូស៊ីបច្ចេកវិទ្យាហិរញ្ញវត្ថុឱ្យបានរឹងមាំ។ ហើយបើពិនិត្យទៅលើទំហំនៃបច្ចេកវិទ្យាហិរញ្ញវត្ថុវិញក៏មានការកើនឡើងផងដែរ។

**រូបភាពទី៩៖** ប្រព័ន្ធអេកូឡូស៊ីបច្ចេកវិទ្យាហិរញ្ញវត្ថុ




**ប្រភព៖** Mekong Strategic Partner 2021

**រូបភាពទី១០៖** ទំហំនៃបច្ចេកវិទ្យាហិរញ្ញវត្ថុនៅកម្ពុជា




**ប្រភព៖** ធនាគារជាតិនៃកម្ពុជា ២០២២ និងនិយ័តករធានារ៉ាប់រងកម្ពុជា ២០២១

ចំពោះទិដ្ឋភាពពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកវិញ ហាក់មានការចាប់អារម្មណ៍ជាខ្លាំងពីគ្រប់ភាគីពាក់ព័ន្ធដោយការអភិវឌ្ឍផ្នែកសំខាន់ៗ នៃប្រព័ន្ធអេកូឡូស៊ីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិច-ត្រូនិកត្រូវបានដាក់បញ្ចូលក្នុងរបៀបវារៈអភិវឌ្ឍន៍ថ្នាក់ជាតិជាបន្តបន្ទាប់។នៅក្នុងយុទ្ធសាស្ត្រពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកបានបរិយាយលម្អិតនូវសមាសធាតុចំនួន៣ ក្នុងចំណោម១០ ក្នុងការជំរុញ និងលើកកម្ពស់ប្រព័ន្ធអេកូឡូស៊ីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកឱ្យកាន់តែប្រសើររួមមាន ១)យុទ្ធសាស្ត្រគោលនយោបាយនិងផ្នែកសម្របសម្រួលស្ថាប័ន, ២) ក្របខណ្ឌច្បាប់ និងបទប្បញ្ញត្តិ និង ៣) បទប្បញ្ញត្តិសម្រាប់សហគ្រាសធុនតូច និងមធ្យម។ សមាសធាតុទាំងបីនឹងធ្វើឱ្យប្រសើរឡើងនូវបរិយាកាសធុរកិច្ចទាំងមូល និងក្របខណ្ឌបទប្បញ្ញត្តិសម្រាប់សហគ្រាសពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកទាំងក្នុងដំណើរការទាក់ទងនឹងការចុះបញ្ជី, ការផ្តល់អាជ្ញាបណ្ណដល់អាជីវកម្មជាពិសេសសហគ្រាសធុនតូច និង មធ្យម, ការទទួលបានព័ត៌មាន, លទ្ធភាពទទួលបានហិរញ្ញប្បទាន និងការគាំទ្រនានា, ការកំណត់អំពីបញ្ហាប្រឈមរបស់សហគ្រាសសម្រាប់ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក និងការលើកទឹកចិត្តដល់សហគ្រាសក្នុងវិស័យនេះផងដែរ។

## **រូបភាពទី១១៖** ទំហំពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកកម្ពុជា




**ប្រភព៖** ក្រសួងពាណិជ្ជកម្ម និង World Development Indicator, Data Reportal និង Statista




**ប្រភព៖** World Development Indicator, Data Reportal និង Statista

### ២.១.៤. ទិដ្ឋភាពនៃការប្រើប្រាស់បច្ចេកវិទ្យារបស់សហគ្រាស

តាមរយៈរបាយការណ៍សង្ខេបរបស់ក្រុមហ៊ុន Meta ឆ្នាំ២០២១ ស្តីពីសហគ្រាសធុនមីក្រូ, តូច និងមធ្យម (MSMEs) និងការប្រើប្រាស់ឧបករណ៍ឌីជីថលក្នុងអំឡុងវិបត្តិនៃជំងឺកូវីដ-១៩, MSMEs ៣៦% ធ្លាប់បានប្រើប្រាស់ដំណោះស្រាយ/សេវាកម្មឌីជីថលមុនការរីករាលដាលនៃជំងឺកូវីដ-១៩ និង ៤៥% បានប្រើប្រាស់ដំណោះស្រាយ/សេវាកម្មឌីជីថលក្នុងឆ្នាំ២០២០។ ៦៦% ប្រើប្រាស់បណ្តាញសង្គម Facebook ដើម្បីសម្របទៅនឹងការរីករាលដាលជំងឺកូវីដ-១៩, ៧៣% បានរាយការណ៍ថាឧបករណ៍ឌីជីថលពិតជាសំខាន់សម្រាប់ប្រតិបត្តិការអាជីវកម្មក្នុងអំឡុងពេលនៃការរីករាលដាលជំងឺកូវីដ-១៩ និង ៤៣% នៃអាជីវកម្មអនឡាញបានរាយការណ៍ថាបណ្តាញសង្គម Facebook គឺជាឧបករណ៍សម្រាប់ទំនាក់ទំនងជាមួយអតិថិជន។

**រូបភាពទី១២៖** ទិដ្ឋភាពនៃការប្រើប្រាស់បច្ចេកវិទ្យារបស់សហគ្រាស




**ប្រភព៖** MSMEs and Digital Tool Use amidst the Covid-19 Pandemic, Cambodia Country Brief, DAI and Meta, 2021.

បើពិនិត្យទៅលើទិន្នន័យខាងលើ, សហគ្រាសភាគច្រើនជាពិសេសសហគ្រាសធុនមីក្រូ, តូច និងមធ្យម (MSMEs) បានប្រើប្រាស់កម្មវិធីនៃប្រព័ន្ធបណ្តាញសង្គមដើម្បីប្រកបអាជីវកម្ម។ ក្នុងន័យនេះ, ការដាក់ឱ្យអនុវត្តច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនឹងនាំមកនូវការផ្លាស់ប្តូរបរិយាកាសនិងរបៀបធ្វើពាណិជ្ជកម្មតាមប្រព័ន្ធបណ្តាញសង្គម (Social Commerce) និងសហគ្រាសមីក្រូមិនផ្លូវការមួយចំនួន។ បើទោះបីជាមិនមានតួលេខពិតប្រាកដច្បាស់លាស់អំពីចំនួនសហគ្រាសដែលប្រកបមុខជំនួញនៅលើបណ្តាញសង្គម និងប្រភពចំណូលរបស់សហគ្រាសទាំងនោះ ក៏ប៉ុន្តែអ្វីដែលអាចសន្និដ្ឋានបាននោះគឺបើពុំមានសកម្មភាពពាណិជ្ជកម្មបែបនេះទេ ប្រជាពលរដ្ឋមួយចំនួនអាចនឹងគ្មានការងារធ្វើ, បាត់បង់ប្រភពចំណូល ហើយនឹងក្លាយជាសម្ពាធមួយដ៏ធ្ងន់ចំពោះប្រព័ន្ធសុខមាលភាពជាតិក្នុងអំឡុងពេលនៃវិបត្តិកូវីដ-១៩។ ក្នុងន័យនេះ, រាជរដ្ឋាភិបាលត្រូវបង្កើនការយកចិត្តទុកដាក់ក្នុងការជំរុញការចាប់យកការប្រើប្រាស់បច្ចេកវិទ្យាឌីជីថល និងត្រូវគិតគូរទៅលើការវិភាជន៍ថវិកាទៅដល់សកម្មភាពជាអាទិភាពដើម្បីគាំទ្រ និងលើកកម្ពស់ដល់សហគ្រាសគ្រប់កម្រិតស្របតាមចក្ខុវិស័យដែលបានដាក់ចេញនៅក្នុងក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និង សង្គមឌីជីថល។

## ២.២. បញ្ហាប្រឈម

បញ្ហាប្រឈមរបស់សហគ្រាសត្រូវបានកំណត់ខុសៗគ្នាទៅតាមការដាក់ចេញនូវក្របខណ្ឌគោលនយោបាយ, យុទ្ធសាស្ត្រ, ផែនការសកម្មភាព និងឯកសារមួយចំនួនដែលជាទូទៅ សហគ្រាសជួបប្រទះបញ្ហាប្រឈមដូចជា ១) កង្វះភាពជាអ្នកដឹកនាំ ការសម្របសម្រួល និងការសម្រេចចិត្តប្រកបដោយប្រសិទ្ធភាពគ្រប់កម្រិត ដូចជាការគាំទ្រសំខាន់ៗពាក់ព័ន្ធនឹងបញ្ហាផ្គត់ផ្គង់ អគ្គិសនី ហេដ្ឋារចនាសម្ព័ន្ធ និងឡូជិស្ទីក ធនធានមនុស្ស និង ជំនាញ ព្រមទាំងការតភ្ជាប់ហេដ្ឋារចនាសម្ព័ន្ធផ្សេងទៀតដូចជាហេដ្ឋារចនាសម្ព័ន្ធឌីជីថលរឹង និងទន់, ២) ការអភិវឌ្ឍមូលដ្ឋានចំណេះដឹងផ្នែកបច្ចេកទេស និង ជំនាញដើម្បីប្រែក្លាយកម្លាំងពលកម្មឱ្យមានជំនាញនិងមានសមត្ថភាពចាប់យកបច្ចេកទេស និងបច្ចេកវិទ្យាខ្ពស់នៅមានកម្រិត, ៣) យន្តការទទួលបានហិរញ្ញប្បទាន, ទុនវិនិយោគ និងការគាំទ្រនានារបស់រាជរដ្ឋាភិបាលត្រូវបានរាំងស្ទះដោយសារចំនួនសហគ្រាសដែលមិនបានចុះបញ្ជីជាផ្លូវការជាពិសេសសហគ្រាសធុនមីក្រូមានចំនួនច្រើន។ ភាពមិនផ្លូវការនៃការចុះបញ្ជីក្នុងចំណោមសហគ្រាស និងចំនួនសហគ្រាសដែលមានបញ្ជីគណនេយ្យនៅមានកម្រិតតិចតួចគឺជាឧបសគ្គរាំងដល់សហគ្រាសមិនអាចទទួលបានឥណទាន, ហិរញ្ញប្បទាន ឬ ទុនវិនិយោគសម្រាប់ពង្រីកសកម្មភាពអាជីវកម្ម ឬ ប្រើប្រាស់បច្ចេកទេសឬបច្ចេកវិទ្យាថ្មី និង ៤), គោលការណ៍លើកទឹកចិត្តផ្នែកពន្ធដារ, គយ និង ការលើកទឹកចិត្តនានារបស់រាជរដ្ឋាភិបាលក៏ត្រូវបានរាំងស្ទះ ដោយសារការគាំទ្ររបស់រាជរដ្ឋាភិបាលចំពោះសកម្មភាពរបស់សហគ្រាសអាចធ្វើទៅបានដរាបណាសហគ្រាសបានចុះបញ្ជីជាផ្លូវការ និងបានរក្សាបញ្ជីគណនេយ្យច្បាស់លាស់សម្រាប់ជាមូលដ្ឋានវាយតម្លៃ និង ៥) ប្រព័ន្ធអេកូឡូស៊ីសហគ្រិនភាពនៅទន់ខ្សោយ និងស្ថិតក្នុងដំណាក់កាលដំបូងនៅឡើយ។

ផ្អែកលើឯកសារស្រាវជ្រាវផ្លូវការមួយស្តីពីបញ្ហាប្រឈមរបស់សហគ្រាសធុនតូចនិងមធ្យមនៅក្នុងប្រទេសសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ (អាស៊ាន) រួមទាំងកម្ពុជាក្នុងការចាប់យកបច្ចេកវិទ្យាឌីជីថលរបស់វិទ្យាស្ថានស្រាវជ្រាវសេដ្ឋកិច្ចសម្រាប់អាស៊ាន និងអាស៊ីបូព៌ា (ERIA) កាលពីឆ្នាំ២០១៩ បានរំលេចនូវបញ្ហាប្រឈមចំនួន៥ ក្នុងនោះរួមមាន១) ចំណេះដឹង និងការយល់ដឹងពីបច្ចេកវិទ្យាឌីជីថល ២) ការគ្រប់គ្រងប្រតិបត្តិការ, ការថែទាំ និងការអភិវឌ្ឍបច្ចេកវិទ្យាឌីជីថល ៣) ភាពស្ទាក់ស្ទើរក្នុងការប្រើប្រាស់បច្ចេកវិទ្យាឌីជីថល ៤) កិច្ចសហប្រតិបត្តិការរវាងរដ្ឋាភិបាល និងវិស័យឯកជនក្នុងការកសាងអភិវឌ្ឍ និងប្រើប្រាស់ថ្នាលឌីជីថល និង ៥) ការយល់ដឹងរបស់សហគ្រាសអំពីគោលនយោបាយរបស់រដ្ឋាភិបាល។

បញ្ហាប្រឈមខាងលើគឺជាបញ្ហាប្រឈមទូទៅដែលបានដកស្រង់ចេញពីឯកសារគោលនយោបាយ និងឯកសារស្រាវជ្រាវមួយចំនួន។ ដោយឡែកសម្រាប់កម្មវិធីបរិវត្តកម្មឌីជីថលសហគ្រាសនេះនឹងផ្តោតទៅលើបញ្ហាប្រឈមចំនួន៦ ចំណុចដែលសហគ្រាសប្រឈមក្នុងការចាប់យកបច្ចេកវិទ្យាឌីជីថលក្នុងនោះរួមមាន ១) ចំណេះដឹង និងការយល់ដឹងពីបច្ចេកវិទ្យាឌីជីថល ២) ការគ្រប់គ្រងប្រតិបត្តិការ, ការថែទាំ និងការអភិវឌ្ឍបច្ចេកវិទ្យាឌីជីថល ៣) ភាពស្ទាក់ស្ទើរក្នុងការប្រើប្រាស់បច្ចេកវិទ្យាឌីជីថល ៤) កិច្ចសហប្រតិបត្តិការរវាងរដ្ឋាភិបាល និងវិស័យឯកជនក្នុងការកសាងអភិវឌ្ឍ និងប្រើប្រាស់ថ្នាលឌីជីថល, ៥) យន្តការទំនាក់ទំនងរបស់សហគ្រាស និង ៦) កង្វះទុនវិនិយោគ។

## ▶ បញ្ហាប្រឈមទី១

**ចំណេះដឹង និងការយល់ដឹងពីបច្ចេកវិទ្យាឌីជីថលរបស់សហគ្រាស**
គឺជាកត្តាចម្បងដែលសហគ្រាសពិបាកក្នុងការសម្រេចចិត្តចាប់យកការប្រើប្រាស់បច្ចេកវិទ្យាឌីជីថលដោយសហគ្រាសមួយចំនួនយល់ឃើញថាពាក្យឌីជីថលូបនីយកម្មមានលក្ខណៈស្មុគស្មាញ និងមានតម្រូវការចំណាយខ្ពស់។ បន្ថែមលើនេះ, ពួកគេយល់ថា សកម្មភាពអាជីវកម្មរបស់ ពួកគេមិនទាន់ត្រូវការបច្ចេកវិទ្យាឌីជីថលនោះទេ ដោយព័ត៌មានដែលពួកគេទទួលបានពីការធ្វើឌីជីថលូបនីយកម្មនៅមានកម្រិត មិនមានលក្ខណៈប្រមូលផ្តុំ មិនច្បាស់លាស់ ហើយបើពួកគេចាប់អារម្មណ៍ក្នុងការចាប់យកការប្រើប្រាស់បច្ចេកវិទ្យាឌីជីថលក៏មិនដឹងទៅស្វែងរកជំនួយប្រឹក្សាយោបល់នៅទីកន្លែងណា។

## ▶ បញ្ហាប្រឈមទី២

**កង្វះខាតធនធានមនុស្ស និងជំនាញក្នុងការគ្រប់គ្រងប្រតិបត្តិការ, ការថែទាំ និងការអភិវឌ្ឍបច្ចេកវិទ្យាឌីជីថល**
មុនពេលសម្រេចចិត្តចាប់យកបច្ចេកវិទ្យាឌីជីថល ម្ចាស់សហគ្រាសត្រូវតែយកចិត្តទុកដាក់ខ្ពស់ទៅលើចំណេះដឹងនិងជំនាញរបស់បុគ្គលិកគ្រប់កម្រិតចាប់ពីកម្រិតមូលដ្ឋានដល់កម្រិតខ្ពស់ ក្នុងការប្រើប្រាស់ និងថែទាំដំណោះស្រាយឌីជីថល (Digital Solutions) ដែលខ្លួនសម្រេចប្រើប្រាស់នៅក្នុងប្រតិបត្តិការអាជីវកម្ម។ ក្នុងន័យនេះ, បើទោះជាម្ចាស់សហគ្រាសសម្រេចចិត្តប្រើប្រាស់ដំណោះស្រាយឌីជីថល ឬសេវាកម្មឌីជីថល ឬចង់ផ្លាស់ប្តូរពីការប្រើប្រាស់បច្ចេកវិទ្យាឌីជីថលក្នុងកម្រិតមូលដ្ឋាន ទៅកម្រិតមធ្យម ឬខ្ពស់ ម្ចាស់សហគ្រាសក៏ត្រូវតែងាកមកមើលធនធានមនុស្សរបស់ខ្លួនថា តើអាចប្រើប្រាស់ ឬទាញយកប្រយោជន៍ជាអតិបរមានៃដំណោះស្រាយឌីជីថលទាំងនោះដែរឬទេ។ ចំពោះសហគ្រាសដែលជាអ្នកផ្តល់សេវាកម្មឌីជីថល ឬដំណោះស្រាយឌីជីថលទៅដល់សហគ្រាសផ្សេង ឬ អ្នកប្រើប្រាស់ ក៏ត្រូវគិតគូរដល់បញ្ហាចំណេះ និងជំនាញនេះដែរ ទើបដំណោះស្រាយឌីជីថលដែលខ្លួនបានបង្កើតអាចទទួលបានជោគជ័យក្នុងទីផ្សារ។

## ▶ បញ្ហាប្រឈមទី៣

### ភាពស្ទាក់ស្ទើរក្នុងការប្រើប្រាស់បច្ចេកវិទ្យាឌីជីថលក្នុងប្រតិបត្តិការអាជីវកម្ម

បើទោះបីជាសហគ្រាសមួយចំនួនយល់ដឹងពីផលប្រយោជន៍នៃការប្រើប្រាស់បច្ចេកវិទ្យាឌីជីថលក៏ដោយ ក៏ពួកគេនៅមានភាពស្ទាក់ស្ទើរក្នុងការប្រើប្រាស់បច្ចេកវិទ្យាឌីជីថលក្នុងប្រតិបត្តិការអាជីវកម្មដោយសារពួកគេមិនទាន់ដឹងច្បាស់ពីរបៀបនៃការប្រើប្រាស់ដំណោះស្រាយឌីជីថលទាំងនោះនៅក្នុងប្រតិបត្តិការអាជីវកម្ម, បារម្ភថាព័ត៌មានរបស់អាជីវកម្មត្រូវលាតត្រដាងទាំងស្រុងដល់អាជ្ញាធរមានសមត្ថកិច្ច និងបារម្ភពីសុវត្ថិភាពទិន្នន័យអាជីវកម្មរបស់ខ្លួន។ ឆ្លើយតបនឹងសំនួរ "តើអ្នកគិតថា អ្វីជាហេតុផលសំខាន់ដែលអ្នកជ្រើសរើសមិនប្រើប្រាស់សេវាកម្មឌីជីថល? នៅក្នុង "ផែនការមេឌីជីថលអាស៊ាន ២០២៥" ដែលប្រជាជាតិអាស៊ានបានរួមគ្នារៀបចំដើម្បីសម្រេចចក្ខុវិស័យប្រែក្លាយអាស៊ានទៅជាតំបន់នាំមុខលើសេដ្ឋកិច្ច និងសហគមន៍ឌីជីថល, ៣៥% បានឆ្លើយថា មកពី "ខ្វះការជឿទុកចិត្ត (Lack of Trust)" ដែលមូលហេតុនេះទាំងសហគ្រាស, អ្នកផ្តល់សេវាឌីជីថល និងអ្នកប្រើប្រាស់ សេវាឌីជីថលនៅតែមានភាពស្ទាក់ស្ទើរក្នុងការចាប់យកបច្ចេកវិទ្យាឌីជីថលនៅក្នុងសកម្មភាពរស់នៅប្រចាំថ្ងៃបើទោះជាពិភពលោកកំពុងស្ថិតនៅក្នុងដំណាក់កាលនៃបដិវត្តន៍ឧស្សាហកម្មជំនាន់៤.០ដែលផ្តោតជាសំខាន់លើបរិវត្តកម្មឌីជីថលក៏ដោយ។

## ▶ បញ្ហាប្រឈមទី៤

### កិច្ចសហប្រតិបត្តិការរវាងរដ្ឋាភិបាល និងវិស័យឯកជនក្នុងការកសាងអភិវឌ្ឍ និងប្រើប្រាស់ថ្នាលឌីជីថលនៅមានកម្រិត

ថ្នាលឌីជីថល (Digital Platform) មានតួនាទីយ៉ាងសំខាន់ក្នុងការជំរុញអោយសហគ្រាសចាប់យកការប្រើប្រាស់បច្ចេកវិទ្យាឌីជីថល។ រាជរដ្ឋាភិបាលបានកសាង និងបង្កើតថ្នាលផ្លាស់ប្តូរទិន្នន័យកម្ពុជា (CamDX) ដើម្បីសម្រួលដល់ការផ្លាស់ប្តូរទិន្នន័យរវាងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានមួយនិងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានមួយទៀតក្នុងវិស័យសាធារណៈ និងជាមួយវិស័យឯកជនក្នុងក្របខណ្ឌអន្តរប្រតិបត្តិការ, ថ្នាលកំណត់សម្គាល់អត្តសញ្ញាណអតិថិជនឌីជីថល (CamDigiKey) ដែលសម្រួលដល់ការកំណត់អត្តសញ្ញាណអតិថិជនឌីជីថល (e-KYC solution) ក្នុងពិភពឌីជីថលនឹងបម្រើផលប្រយោជន៍ដល់វិស័យឯកជនជាពិសេសវិស័យសេដ្ឋកិច្ច, ហិរញ្ញវត្ថុ, ធុរកិច្ច និងធនាគារ និងការដាក់ឱ្យដំណើរការនូវប្រព័ន្ធចុះបញ្ជីអាជីវកម្មតាមថ្នាលបច្ចេកវិទ្យាព័ត៌មាន (Online Business Registration) ក៏ជាជំហានវិជ្ជមានមួយសំខាន់ក្នុងការជំរុញការធ្វើឌីជីថលូបនីយកម្មរបស់សហគ្រាសជារួម ក៏ដូចជាការជំរុញទម្រង់នីយកម្ម (Formalization) នៃព័ត៌មានសហគ្រាសទាំងអស់ផងដែរ។ បើទោះជារាជរដ្ឋាភិបាលបានបង្កើតនូវថ្នាលគ្រឹះដែលជាឃ្នាស់ដ៏សំខាន់ក្នុងការជំរុញការចាប់យកបច្ចេកវិទ្យាឌីជីថល ប៉ុន្តែទំហំនៃការប្រើប្រាស់ថ្នាលទាំង នោះពីវិស័យឯកជន និងប្រជាពលរដ្ឋនៅមានកម្រិតទាបនៅឡើយ ហើយការចូលរួមប្រើប្រាស់ពីវិស័យសាធារណៈក៏ត្រូវបង្កើនល្បឿនផងដែរ។ ចំពោះវិស័យឯកជន ពិសេសសហគ្រាស ឬធុរកិច្ចថ្មីៗបានខិតខំកសាង និងបង្កើតដំណោះស្រាយឌីជីថលថ្មីៗ (Supply-side) ជាច្រើន ប៉ុន្តែដំណោះស្រាយឌីជីថល ឬថ្នាលឌីជីថលមួយចំនួនមិនត្រូវបានគាំទ្រ ឬប្រើប្រាស់ដោយសារសហគ្រាស ឬធុរកិច្ចថ្មីទាំងនោះមិនបានផ្សព្វផ្សាយអោយបានទូលំទូលាយទៅកាន់ទីផ្សារ។ ដូច្នេះរាជរដ្ឋាភិបាល និងវិស័យឯកជនត្រូវបង្កើនកិច្ចសហប្រតិបត្តិការ និងបំពេញបន្ថែមឱ្យគ្នានូវការកសាងអភិវឌ្ឍ និងប្រើប្រាស់ថ្នាលឌីជីថល។

## បញ្ហាប្រឈមទី៥

### យន្តការទំនាក់ទំនងរវាងសហគ្រាស

យន្តការរវាងអ្នកផ្តល់ និងអ្នកប្រើប្រាស់ដំណោះស្រាយឌីជីថលនៅមានកម្រិត។ សហគ្រាសធុនតូច និងមធ្យមទាំងអ្នកផ្តល់ដំណោះស្រាយឌីជីថល (Supply Side) និងអ្នកប្រើប្រាស់សេវាកម្មឌីជីថល (Demand Side) នៅមិនទាន់រកយន្តការក្នុងការផ្តល់ព័ត៌មានឱ្យគ្នាទៅវិញទៅមកនៅឡើយដោយអ្នកផ្តល់មិនដឹងផ្តល់អោយអ្នកណាហើយអ្នកត្រូវការមិនដឹងទៅរកអ្នកផ្តល់ដំណោះស្រាយដែលអាចធានាបាននូវដំណោះស្រាយល្អ ប្រកបដោយជំនឿទុកចិត្តបាននៅកន្លែងណា។ បន្ថែមលើនេះ វិស័យឯកជនក៏នៅមិនទាន់ដឹងច្បាស់ពីដំណោះស្រាយឌីជីថលដែលមានស្រាប់ដែលរាជរដ្ឋាភិបាលបានបង្កើត គោលនយោបាយជំរុញនិង គាំទ្រការចាប់យកបច្ចេកវិទ្យាឌីជីថលរបស់សហគ្រាសដោយយន្តការគាំទ្រទាំងអស់មិនមានលក្ខណៈប្រមូលផ្តុំនៅកន្លែងតែមួយ ហើយការផ្សព្វផ្សាយរបស់រាជរដ្ឋាភិបាលក៏នៅមានកម្រិត។ ជារួមនៅពេលវិស័យឯកជន ដែលត្រូវបានចាត់ទុកជាក្បាលម៉ាស៊ីនក្នុងការរួមចំណែកអភិវឌ្ឍន៍សង្គម-សេដ្ឋកិច្ចមិនបានដឹងពីយន្តការគាំទ្ររបស់រាជរដ្ឋាភិបាលដែលបានដាក់ចេញ, នោះកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលក្នុងការជំរុញបរិវត្តកម្មឌីជីថលសហគ្រាសក៏មិនអាចសម្រេចបានតាមគោលដៅនោះដែរ។

## បញ្ហាប្រឈមទី៦

### កង្វះទុនវិនិយោគ

បញ្ហានេះគឺកើតមានជាទូទៅសម្រាប់ការចាប់ផ្តើម អាជីវកម្មជាពិសេសធុរកិច្ចថ្មី ហើយការខ្វះទុនវិនិយោគនៅក្នុងកម្មវិធីនេះគឺសំដៅទៅលើកង្វះទុនក្នុងការប្រើប្រាស់ផលិតផលឬសេវាកម្មឌីជីថលដើម្បីធ្វើទំនើបកម្មប្រតិបត្តិការអាជីវកម្ម,ការខ្វះដើមទុនសម្រាប់អភិវឌ្ឍន៍ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ឬបច្ចេកវិទ្យាឌីជីថលដោយសារកម្ពុជាស្ថិតក្នុងចំណោមប្រទេសដែលប្រើប្រាស់បច្ចេកវិទ្យា និងធនធានមនុស្សជំនាញឌីជីថលនៅមានកម្រិតដែលធ្វើអោយ សហគ្រាសមួយចំនួនពុំមានលទ្ធភាពគ្រប់គ្រាន់ក្នុងការប្រើប្រាស់ ឬ អភិវឌ្ឍន៍ប្រព័ន្ធចាំបាច់ទាំងអស់នោះ។

# ៣

# អំពីកម្មវិធីបរិវត្តកម្ម
# ឌីជីថលសហគ្រាស

## ៣.អំពីកម្មវិធីបរិវត្តកម្មឌីជីថលសហគ្រាស

**រូបភាពទី១៣៖** ក្របខណ្ឌរួមនៃការអនុវត្តកម្មវិធីបរិវត្តកម្មឌីជីថលសហគ្រាស




### ៣.១. គោលបំណង

កម្មវិធីបរិវត្តកម្មឌីជីថលសហគ្រាស ត្រូវបានរៀបចំឡើងក្នុងគោលបំណងពង្រឹងសមត្ថភាពឌីជីថលរបស់សហគ្រាស តាមរយៈការធ្វើបរិវត្តកម្មឌីជីថលសហគ្រាស ដើម្បីជំរុញឱ្យសហគ្រាសគ្រប់កម្រិតអាចក្លាយជាភ្នាក់ងារជំរុញសកម្មនៅក្នុងសេដ្ឋកិច្ច និងធុរកិច្ចឌីជីថល និងបង្កើនការរួមចំណែករបស់វិស័យឯកជនក្នុងការអភិវឌ្ឍសេដ្ឋកិច្ច និងធុរកិច្ចឌីជីថលប្រកបដោយភាពធន់, ចីរភាព និងបរិយាបន្ន។

## ៣.២. គោលដៅ

ការកំណត់គោលដៅដែលជាលទ្ធផលរំពឹងទុកនៃការដាក់ឱ្យអនុវត្តកម្មវិធីបរិវត្តកម្មឌីជីថលសហគ្រាសមានចំនួន៣ ដូចខាងក្រោម៖

១ បង្កើនការផ្តល់ផលិតផល / សេវាកម្មឌីជីថលប្រកបដោយគុណភាពតាមវិស័យនៅលើថ្នាលបរិវត្តកម្មឌីជីថលសហគ្រាស

២ លើកកម្ពស់លទ្ធភាពទទួលបានព័ត៌មាន, បង្កើនការយល់ដឹងអំពីបរិវត្តកម្មឌីជីថល និង ការបណ្តុះបណ្តាលដល់សហគ្រាស

៣ លើកកម្ពស់ការប្រើប្រាស់ថ្នាលឌីជីថលរបស់រាជរដ្ឋាភិបាល

## ៣.៣.សកម្មភាពអាទិភាព

កម្មវិធីបរិវត្តកម្មឌីជីថលសហគ្រាសនឹងផ្តោតទៅលើសកម្មភាពធំៗចំនួន៥ ដើម្បីសម្រេចតាមគោលដៅ និងគោលបំណងរបស់កម្មវិធីដែលបានដាក់ចេញ។

**រូបភាពទី១៤៖** ទំនាក់ទំនងសកម្មភាពទាំង៥នៃកម្មវិធីបរិវត្តកម្មឌីជីថលសហគ្រាស



### ៣.៣.១. ការលើកកម្ពស់ឌីជីថលូបនីយកម្មនៃប្រតិបត្តិការធុរកិច្ច និងយុទ្ធសាស្ត្រទីផ្សាររបស់សហគ្រាស (General Business and Marketing Functions)

សម្ទុះកំណើននៃការចាប់យកឌីជីថល នឹងជំរុញឱ្យមានតម្រូវការធំធេងនូវផលិតផល និងសេវាឌីជីថលស្ទើរគ្រប់វិស័យដែលក្នុងនោះ បច្ចេកវិទ្យាឌីជីថលនឹងវិវឌ្ឍខ្លួនទៅជាកត្តាគន្លឹះដ៏សំខាន់ក្នុងការបង្កើតតម្លៃបន្ថែមសម្រាប់ផលិតផល និងសេវាដែលមានស្រាប់។ ម្យ៉ាងវិញទៀត ការវិវឌ្ឍកាន់តែឆាប់រហ័សនៃបច្ចេកវិទ្យាអាចនឹងធ្វើឱ្យគំរូធុរកិច្ចនៃសហគ្រាសនៅក្នុងវិស័យមួយចំនួន ត្រូវបាត់បង់តម្លៃ និងតម្រូវការ។ និន្នាការនេះនឹងជំរុញឱ្យសហគ្រាសគ្រប់វិស័យត្រូវគិតគូរក្នុងការទាញយកអត្ថប្រយោជន៍ និងការបង្កើតតម្លៃបន្ថែមពីនវានុវត្តន៍នៃបច្ចេកវិទ្យាក៏ដូចជាការរក្សាបាននូវមូលដ្ឋានអាជីវកម្មក្នុងបរិការណ៍នៃបរិវត្តកម្មឌីជីថលតាមរយៈ (១) ការវាយតម្លៃកម្រិតត្រៀមខ្លួនចាប់យកឌីជីថលរបស់សហគ្រាស (Diagnostic enterprise digital readiness) តាមវិស័យ (២) ការរៀបចំផែនទីចង្អុលផ្លូវស្តីពីដំណោះស្រាយឌីជីថល (Digital Solutions Roadmap) ដើម្បីកំណត់ប្រភេទផលិតផល ឬសេវាកម្មដែលជំរុញឌីជីថលូបនីយកម្មតាមប្រភេទអាជីវកម្ម, ទំហំអាជីវកម្ម និងលទ្ធភាព និងតម្រូវការរបស់ម្ចាស់អាជីវកម្ម និង (៣) ការរៀបចំផែនទីបង្ហាញផ្លូវស្តីពីការបណ្តុះបណ្តាលបច្ចេកវិទ្យាឌីជីថល (Digital Training Roadmap) ដើម្បីជួយដល់សហគ្រាសក្នុងការបណ្តុះចំណេះដឹង និងជំនាញដល់បុគ្គលិកគ្រប់កម្រិតចាប់ពីកម្រិតមូលដ្ឋានដល់កម្រិតខ្ពស់ក្នុងការប្រើប្រាស់ថែទាំនិងអភិវឌ្ឍន៍ដំណោះស្រាយឌីជីថល (Digital Solutions) ដែលត្រូវបានជ្រើសរើសក្នុងប្រតិបត្តិការអាជីវកម្ម។

#### ក. ការវាយតម្លៃកម្រិតត្រៀមខ្លួនចាប់យកឌីជីថលរបស់សហគ្រាសតាមវិស័យ

ដើម្បីវាយតម្លៃកម្រិតត្រៀមខ្លួនរបស់សហគ្រាសក្នុងការចាប់យកឌីជីថលតាមវិស័យនីមួយៗ, កម្រងសំនួរនឹងត្រូវបានរៀបចំឡើង ហើយសហគ្រាសគ្រប់កម្រិត (មីក្រូ, តូច, មធ្យម និងធំ) អាចវាយតម្លៃកម្រិតត្រៀមខ្លួនអនឡាញតាមរយៈថ្នាលឌីជីថល (Digital Platform) ដែលបានបង្កើតក្នុងសកម្មភាពទី៣នៃកម្មវិធីនេះនិងអាចសាកសួរព័ត៌មានស្តីពីការប្រើប្រាស់ថ្នាលឌីជីថលនៅមជ្ឈមណ្ឌលបរិវត្តកម្មឌីជីថលសហគ្រាសដោយផ្ទាល់នៅសកម្មភាពទី៤នៃកម្មវិធីនេះផងដែរ។ ការរៀបចំកម្រងសំណួរនេះនឹងរៀបចំទៅតាមកម្រិតនៃការចាប់យកឌីជីថលរបស់សហគ្រាសប៉ុន្តែបញ្ហាប្រឈមសម្រាប់ការងារនេះគឺការបែងចែកកម្រិតនៃការចាប់យកឌីជីថល (Digital Adoption) ត្រូវបានកំណត់ខុសៗគ្នាទៅតាមបរិការណ៍នៃការចាប់យកឌីជីថលរបស់ប្រទេសនីមួយៗដោយពុំមានក្របខណ្ឌរួមច្បាស់លាស់ហើយដំណោះស្រាយឌីជីថលថ្មីៗមួយចំនួនពុំទាន់បានចាត់ថ្នាក់នៅក្នុងកម្រិតណាមួយនៅឡើយ។ បើផ្អែកតាមការកំណត់របស់វិទ្យាស្ថានស្រាវជ្រាវសេដ្ឋកិច្ចសម្រាប់អាស៊ាន និងអាស៊ីបូព៌ា (ERIA) កាលពីឆ្នាំ២០១៩, កម្រិតនៃការចាប់យកបច្ចេកវិទ្យាឌីជីថលត្រូវបានបែងចែកជាបីកម្រិតរួមមាន ១) កម្រិតមូលដ្ឋាន (Basic Digital Technology -BDT) ដែលក្នុងនោះរួមមាន ឧបករណ៍មូលដ្ឋាន (Basic Devices) និង សុសវែមូលដ្ឋាន (Basic Software), ២) កម្រិតមធ្យម (Intermediate Digital Technology (IDT) រួមមាន ការទូទាត់តាមអេឡិចត្រូនិក (E-Payment) និង វត្តមានអនឡាញ (Online Presence) ដូចជាបណ្តាញសង្គម (Social Media), ថ្នាលឌីជីថល (Digital Platform) និង គេហទំព័រ (Website) និង ៣) កម្រិតខ្ពស់

(Advanced Digital Technology-ADT) រួមមាន សុសវែរកម្រិតខ្ពស់ដូចជា សុសវែរឯកទេស (Specialized Software), Enterprise resource planning (ERP), គណនេយ្យ/ហិរញ្ញវត្ថុ (Accounting/Finance), ការធ្វើទីផ្សារ (Marketing), ការគ្រប់គ្រងទំនាក់ទំនងអតិថិជន (CRM), និងសុសវែរវិភាគទិន្នន័យ (Data analysis) ។

**រូបភាពទី១៥៖** ការប្រើប្រាស់ផលិតផល/សេវាកម្មឌីជីថលទៅតាមកម្រិត




**ប្រភព៖** ERIA ក្នុងឆ្នាំ២០១៩

ជារួម, ការរៀបចំ និងធ្វើបច្ចុប្បន្នភាពកម្រងសំណួរត្រូវផ្អែកលើមូលដ្ឋានស្រាវជ្រាវច្បាស់លាស់ ដែលដាក់ចេញនៅក្នុងសកម្មភាពទី២នៃកម្មវិធីបរិវត្តកម្មឌីជីថលសហគ្រាសនេះដើម្បីកំណត់ឱ្យបាន ជាក់លាក់អំពីកម្រិតនៃការចាប់យកឌីជីថលរបស់សហគ្រាសតាមវិស័យសម្រាប់ជាមូលដ្ឋានក្នុងការផ្ដល់ ការគាំទ្រពីរាជរដ្ឋាភិបាល និងដៃគូពាក់ព័ន្ធក្នុងការជំរុញការប្រើប្រាស់បច្ចេកវិទ្យាឌីជីថលឱ្យត្រូវតាម កម្រិតនៃភាពរួចរាល់របស់សហគ្រាស និងចំទិសដៅ ។

## ខ. ការរៀបចំផែនទីចង្អុលផ្លូវស្ដីពីដំណោះស្រាយឌីជីថល (Digital Solution Roadmap)

ការកំណត់ប្រភេទផលិតផល ឬសេវាកម្មដែលជំរុញឌីជីថលូបនីយកម្មតាមប្រភេទអាជីវកម្ម, ទំហំអាជីវកម្ម និងលទ្ធភាព និងតម្រូវការរបស់ម្ចាស់អាជីវកម្មក៏ត្រូវសិក្សាលម្អិត និងកំណត់ឱ្យបាន ច្បាស់លាស់តាមរយៈការរៀបចំផែនទីចង្អុលផ្លូវស្ដីពីដំណោះស្រាយឌីជីថល។ ផែនទីចង្អុលផ្លូវនេះនឹង ត្រូវប្រើប្រាស់ជាមគ្គុទេសន៍សម្រាប់សហគ្រាសគ្រប់កម្រិតក្នុងការរៀបចំផែនការនៃការប្រើប្រាស់បច្ចេកវិទ្យា ឌីជីថល (Digital Journey) នៅគ្រប់ដំណាក់កាលនៃកំណើន។ ដំណាក់កាលទី១៖ ការចាប់ ផ្ដើមប្រើប្រាស់ដំណោះស្រាយឌីជីថលកម្រិតមូលដ្ឋាន(Kickstart the Digital Journey) ដើម្បី លើកកម្ពស់ប្រតិបត្តិការអាជីវកម្ម, ដំណាក់កាលទី២៖ ការថ្លក់ ឬ ធ្វើសមាហរណកម្មក្នុងខ្សែច្រវាក់

តម្លៃ (Integrate in the Value Chain) ដើម្បីពង្រីកអាជីវកម្មតាមរយៈការតភ្ជាប់ជាមួយថ្នាលដែលមានលក្ខណៈសមាហរណកម្មក្នុងន័យលើកកម្ពស់ប្រសិទ្ធភាពប្រតិបត្តិការ និង ការចាប់យកឱកាសថ្មីៗ និងដំណាក់កាលទី៣៖ ការពង្រឹងសមត្ថភាពប្រកួតប្រជែង (Strengthen Competitive Edge) ដើម្បីជំរុញការប្រើប្រាស់បច្ចេកវិទ្យាទំនើបរបស់សហគ្រាស។ ក្នុងន័យនេះ, ការរៀបចំផែនទីចង្អុលផ្លូវស្តីពីដំណោះស្រាយឌីជីថលត្រូវកំណត់ប្រភេទផលិតផល ឬ សេវាកម្មដែលជំរុញឌីជីថលូបនីយកម្មទៅតាមដំណាក់កាលនីមួយៗឱ្យបានច្បាស់លាស់ដើម្បីផ្តល់ភាពងាយស្រួលដល់សហគ្រាសក្នុងការសម្រេចចិត្តជ្រើសរើសផលិតផលឬសេវាកម្មឌីជីថលទាំងនោះ។

**រូបភាពទី១៦ ៖** ការរៀបចំផែនទីចង្អុលផ្លូវស្តីពីដំណោះស្រាយឌីជីថលទៅតាមដំណាក់កាលនៃកំណើន




### គ.ការរៀបចំផែនទីចង្អុលផ្លូវស្តីពីការបណ្តុះបណ្តាលបច្ចេកវិទ្យាឌីជីថល (Digital Training Roadmap)

បន្ទាប់ពីកម្រងសំណួរស្តីពីការវាយតម្លៃកម្រិតត្រៀមខ្លួន និងការកំណត់ ប្រភេទផលិតផល ឬ សេវាកម្មឌីជីថលទៅតាមកម្រិតត្រៀមខ្លួន និងតម្រូវការទៅតាមវិស័យអាទិភាពបានបញ្ចប់រួចរាល់, ការរៀបចំផែនទីបង្ហាញផ្លូវស្តីពីការបណ្តុះបណ្តាលបច្ចេកវិទ្យាឌីជីថលក៏ត្រូវបានគិតគូរនឹងរៀបចំនៅក្នុងសកម្មភាពទី១នៃកម្មវិធីនេះផងដែរ។ផែនទីបង្ហាញផ្លូវនេះត្រូវបានរៀបចំឡើងក្នុងគោលបំណងណែនាំដល់សហគ្រាសក្នុងការរៀបចំផែនការបណ្តុះបណ្តាលទាក់ទងនឹងចំណេះ និងជំនាញដល់បុគ្គលិកក្នុងការប្រើប្រាស់បច្ចេកទេសឌីជីថលចាប់ពីកម្រិតមូលដ្ឋានទៅកម្រិតខ្ពស់។ ការងារបណ្តុះបណ្តាលគឺជាការងារសំខាន់ដែលតម្រូវឱ្យមានអ្នកជំនាញការដែលមានបទពិសោធន៍ និងជំនាញឌីជីថលច្បាស់លាស់មកផ្តល់ការបណ្តុះបណ្តាលដល់ Business Intermediaries (BIs) សំខាន់ៗ និង អ្នកជំនាញការក្នុងស្រុកមួយចំនួន (Local SME experts) ដើម្បីអាចផ្តល់នូវការបណ្តុះបណ្តាលស្របតាមស្តង់ដារច្បាស់លាស់ប្រកបដោយវិជ្ជាជីវៈ,ផ្តល់ការបណ្តុះបណ្តាលជាក្រុម(Group Training)

ផ្អែកតាមប្រភេទអាជីវកម្ម និងវិស័យអាទិភាព និងយន្តការបណ្ដុះបណ្ដាលផ្សេងៗទៀត។ តារាងខាងក្រោមនេះ ជាឧទាហរណ៍នៃការរៀបចំផែនទីបង្ហាញផ្លូវស្ដីពីការបណ្ដុះបណ្ដាលបច្ចេកវិទ្យាឌីជីថលទៅតាមកម្រិត និងដំណាក់កាលនៃការប្រើប្រាស់បច្ចេកវិទ្យាឌីជីថលក្នុងអនុវិស័យផលិតចំណីអាហារ (Food Manufacturing)។

**តារាងទី២៖** ឧទាហរណ៍នៃការរៀបចំផែនការបណ្ដុះបណ្ដាលបច្ចេកវិទ្យាឌីជីថលក្នុងអនុវិស័យផលិតចំណីអាហារ

| | | ដំណាក់កាលក្នុងការចាប់យកឌីជីថល (ឧទាហរណ៍: អនុវិស័យផលិតម្ហូបអាហារ) | | |
|---|---|---|---|---|
| | | ដំណាក់កាលទី១ | ដំណាក់កាលទី២ | ដំណាក់កាលទី៣ |
| កម្មវិធីបណ្ដុះបណ្ដាល | **បច្ចេកវិទ្យាកម្រិតមូលដ្ឋាន:** សម្រាប់បុគ្គលិកទាំងអស់ | ការគ្រប់គ្រងការដឹកជញ្ជូន | វត្តមាននៅលើគេហទំព័រសម្រាប់ទីផ្សារឌីជីថល | ការប្រើប្រាស់ម៉ាស៊ីនស្វ័យប្រវត្តិ |
| | | ការគ្រប់គ្រងលទ្ធកម្ម និងសម្ភារៈ | ស្វ័យប្រវត្តិកម្ម និងឌីជីថលូបនីយកម្មក្នុងការផលិតម្ហូបអាហារ | ចាប់ផ្ដើមក្នុងការប្រើប្រាស់ការវិភាគព្យាករណ៍សម្រាប់ការថែទាំ |
| | **បច្ចេកវិទ្យាកម្រិតខ្ពស់ :** សម្រាប់និយោជិតដែលកំពុងប្រើប្រាស់ ឬស្វែងរកបច្ចេកវិទ្យាឌីជីថលក្នុងការងារ | ការព្យាករណ៍ទិន្នន័យ | ការអភិវឌ្ឍប្រព័ន្ធតបឆាតស្វ័យប្រវត្តិ | ការយល់ដឹងអំពី Cloud computing |
| | | សន្តិសុខសាយប័រ | ការរចនា និងការអភិវឌ្ឍ Augmented reality | Deep learning with Python |

## ៣.៣.២.ការស្រាវជ្រាវ និងរៀបចំផែនការបរិវត្តកម្មឌីជីថលសហគ្រាសតាមវិស័យ

ការធ្វើឌីជីថលូបនីយកម្ម និងការធ្វើបរិវត្តកម្មឌីជីថលមានការវិវឌ្ឍមិនស្មើគ្នានោះទេ ដោយវិស័យខ្លះមានការវិវឌ្ឍក្នុងកម្រិតមួយ ហើយវិស័យខ្លះទៀតហាក់បីដូចជាមិនមានការវិវឌ្ឍសោះ ដូច្នេះ សកម្មភាពទី២នេះ នឹងសិក្សាស្រាវជ្រាវជាប្រចាំទៅលើតម្រូវការឧបករណ៍ឌីជីថល (digital tool) និងការវិវត្តថ្មីៗ នៃបច្ចេកវិទ្យាឌីជីថលដែលសហគ្រាសត្រូវការ និងរៀបចំជារបាយការណ៍ស្ដីពីការស្រាវជ្រាវ, អត្ថបទខ្លីៗ, ព័ត៌មានចាំបាច់សំខាន់ៗដើម្បីធ្វើជាមូលដ្ឋានក្នុងការរៀបចំផែនការចាប់យកឌីជីថលរបស់សហគ្រាសតាមវិស័យឱ្យបានគ្រប់ជ្រុងជ្រោយគួបផ្សំនឹងការកាត់បន្ថយនូវផលប៉ះពាល់អវិជ្ជមាននានាបណ្ដាល មកពីបច្ចេកវិទ្យាឌីជីថល។ ដើម្បីកាត់បន្ថយគម្លាតនៃការចាប់យកឌីជីថលតាមវិស័យការស្រាវជ្រាវឬការរៀបចំផែនការបរិវត្តកម្មឌីជីថលសហគ្រាសគួរផ្ដល់ការគាំទ្រឬគិតគូរទៅតាមកម្រិតអាជីវកម្ម និងវិស័យអាទិភាពមួយចំនួនដូចមានបង្ហាញក្នុងតារាងពីរ៉ាមីតខាងក្រោម៖

**រូបភាពទី១៧៖** ពីរ៉ាមីតនៃការគាំទ្រផ្អែកតាមទំហំអាជីវកម្ម និងវិស័យអាទិភាព




បន្ថែមលើនេះ សកម្មភាពទី២នេះ នឹងបន្តរៀបចំ និងធ្វើបច្ចុប្បន្នភាពកម្រងសំនួរក្នុងការវាយតម្លៃការត្រៀមខ្លួនរបស់សហគ្រាសក្នុងការចាប់យកឌីជីថលតាមរយៈការសិក្សាស្រាវជ្រាវបន្ថែមទៅលើបច្ចេកវិទ្យាថ្មីៗនិងវិវត្តតឈប់ឈរនៃបច្ចេកវិទ្យាឌីជីថលដែលមិនអាចកំណត់បាននៅក្នុងដំណាក់កាលចាប់ផ្តើមអនុវត្តកម្មវិធី។

### ៣.៣.៣. ការអភិវឌ្ឍថ្នាលបរិវត្តកម្មឌីជីថលសហគ្រាស ( Enterprises Go Digital Platform)

ដើម្បីជំរុញសម្ទុះកំណើនសេដ្ឋកិច្ចថ្មី និងលើកកម្ពស់សុខមាលភាពសង្គម, ការរៀបចំមូលដ្ឋានគ្រឹះជំរុញការទទួលយក និងការធ្វើបរិវត្តកម្មឌីជីថលនៅក្នុងគ្រប់តួអង្គសង្គមទាំងរដ្ឋ, ពលរដ្ឋ និងធុរជនគឺជាកត្តាចាំបាច់។ ថ្នាលឌីជីថល (Digital Platform) ត្រូវបានកំណត់ជាមូលដ្ឋាន និងជាស្នូលនៃការចាប់យកឌីជីថល និងការធ្វើបរិវត្តកម្មឌីជីថល។ “ថ្នាលឌីជីថល” គឺសំដៅទៅលើប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានដែលអាចប្រើប្រាស់រួមគ្នាក្នុងគោលបំណងតែមួយ។ ថ្នាលឌីជីថលដែលបានរៀបចំនេះគឺជាសកម្មភាពស្នូលក្នុងចំណោមសកម្មភាពទាំង៥ នៃកម្មវិធីទាំងមូលដោយថ្នាលនេះជាកន្លែងប្រមូលផ្តុំនូវទិន្នន័យឬព័ត៌មានដែលប្រមូលបានពីសកម្មភាពទាំង៤ផ្សេងទៀតសម្រាប់ជាប្រយោជន៍ដល់សហគ្រាសក្នុងការចាប់យកបច្ចេកវិទ្យាឌីជីថល។ជាយន្តការជាក់លាក់សហគ្រាសផ្តល់សេវាកម្មក្នុងស្រុកដែលមានគុណវុឌ្ឍិគ្រប់គ្រាន់ នឹងត្រូវបានជ្រើសរើស (Pre-Approved Solutions) ដើម្បីបំពេញតួនាទីជាអ្នកផ្តល់ផលិតផលឬសេវាកម្មទាំងនោះទៅតាមកម្រិតត្រៀមខ្លួនចាប់យកឌីជីថលរបស់សហគ្រាសនីមួយៗ។ បន្ថែមលើនេះ, សហគ្រាសដែលត្រូវបានជ្រើសរើស នឹងទទួលបានការបណ្តុះបណ្តាលក្នុងការប្រើប្រាស់ផលិតផលឬសេវាកម្មទាំងនោះ។ ជារួម, ថ្នាលឌីជីថលនេះ នឹងក្លាយជាកន្លែងប្រមូលផ្តុំមួយ(One Stop Shop)និងជាកន្លែងដែលផ្គូរផ្គងរវៀងអ្នកផ្តល់និងអ្នកត្រូវការដំណោះស្រាយឌីជីថលទៅតាមកម្រិតត្រៀមខ្លួន។ បន្ថែមលើនេះ សហគ្រាសអាចវាយតម្លៃពីកម្រិតត្រៀមខ្លួន (Digital Readiness Assessment) និងអាចស្វែងរកដំណោះស្រាយឌីជីថលដែលស៊ីគ្នានឹងកម្រិតត្រៀមខ្លួនតាមអនឡាញតាមរយៈថ្នាលឌីជីថលដែលបាននិងកំពុងបង្កើតឡើងនេះ។

### ៣.៣.៤. ការបង្កើតមជ្ឈមណ្ឌលបរិវត្តកម្មឌីជីថលសហគ្រាស

មជ្ឈមណ្ឌលបរិវត្តកម្មឌីជីថលសហគ្រាសនឹងដើរតួនាទីក្នុងការផ្តល់ព័ត៌មានជូនម្ចាស់សហគ្រាសដែលមានបំណងចាប់ផ្តើមដំណើរការបរិវត្តកម្មឌីជីថល។ បន្ថែមលើនេះ មជ្ឈមណ្ឌលនេះនឹងជួយដល់សហគ្រាស ក្នុងការវាយតម្លៃកម្រិតត្រៀមខ្លួនចាប់យកឌីជីថល (Digital Readiness) និងជួយសហគ្រាស កំណត់ប្រភេទផលិតផល ឬសេវាកម្មដែលជំរុញឌីជីថលូបនីយកម្ម តាមរយៈការប្រើប្រាស់ថ្នាលឌីជីថលដែលបានរៀបចំក្នុងសកម្មភាពទី៣។ ជារួម, មជ្ឈមណ្ឌលគឺជាទីតាំងរូបវន្តសម្រាប់ផ្តល់ព័ត៌មាន (help desk service), ប្រើប្រាស់ថ្នាលឌីជីថល, ផ្តល់ប្រឹក្សាយោបល់ដល់សហគ្រាសដែលមានបំណងធ្វើបរិវត្តកម្មឌីជីថល និង ផ្តល់នូវការបណ្តុះបណ្តាលសហគ្រាសក្នុងការចាប់យកឌីជីថល។ មជ្ឈមណ្ឌលនេះនឹងមានការិយាល័យកណ្តាលមួយនៅរាជធានីភ្នំពេញ ហើយនឹងពង្រីកវិសាលភាពទៅបណ្តាលខេត្តសក្តានុពលផ្សេងទៀតនាពេលអនាគតដើម្បីបង្កើនសមត្ថភាពឌីជីថលរបស់សហគ្រាសតាមបណ្តាប៉ូលសេដ្ឋកិច្ច។

### ៣.៣.៥. ការរៀបចំយុទ្ធនាការថ្នាក់ជាតិលើការផ្សព្វផ្សាយ និងការបង្កើនការយល់ដឹង

ផ្អែកលើឯកសារស្រាវជ្រាវរបស់ វិទ្យាស្ថានស្រាវជ្រាវសេដ្ឋកិច្ចសម្រាប់អាស៊ាន និងអាស៊ីបូព៌ា (ERIA) នៅឆ្នាំ២០១៩ដែល បានបង្ហាញថា សហគ្រាសធុនតូច និងមធ្យមប្រមាណតែ ៣៤% ប៉ុណ្ណោះដែលបានដឹងពីគោលនយោបាយ និងយន្តការគាំទ្ររបស់រាជរដ្ឋាភិបាលដែលការណ៍នេះបានបង្អាក់ដល់ការទាញយកផលប្រយោជន៍ពីគោលនយោបាយលើកទឹកចិត្តឬយន្តការគាំទ្រទាំងហិរញ្ញវត្ថុ និងមិនមែនហិរញ្ញវត្ថុដែលរាជរដ្ឋាភិបាលបានដាក់ចេញ។ ក្នុងន័យនេះ, ការខិតខំរៀបចំគោលនយោបាយ ឬកម្មវិធីគាំទ្រនានារបស់រាជរដ្ឋាភិបាលក្នុងការគាំទ្រ និងសម្រួលដល់បរិយាកាសធុរកិច្ច ឬសំដៅដល់ការធ្វើបរិវត្តកម្មឌីជីថលសហគ្រាសត្រូវធ្វើដំណាលគ្នានឹងការរៀបចំយុទ្ធនាការផ្សព្វផ្សាយនិងការបង្កើនការយល់ដឹង ដល់សហគ្រាស ដើម្បីអាចឱ្យសហគ្រាសអាចទាញយកអត្ថប្រយោជន៍ជាអតិបរមាពីវិធានការគោលនយោបាយឬយន្តការគាំទ្រទាំងនោះ។ ដូច្នេះ សកម្មភាពទី៥នៃកម្មវិធីបរិវត្តកម្មឌីជីថលសហគ្រាសនេះគឺជាសកម្មភាពមួយសំខាន់ដែលអាចញ៉ាំងឱ្យសហគ្រាសអាចទទួលបានព័ត៌មានពេញលេញគ្រប់ជ្រុងជ្រោយ និងអាចជឿទុកចិត្តបាន។ ប៉ុន្តែដើម្បីអាចសម្រេចការងារនេះបាន តម្រូវការក្នុងការរៀបចំយុទ្ធសាស្ត្រផ្សព្វផ្សាយ (Outreach strategy), ការរៀបចំយុទ្ធនាការថ្នាក់ជាតិលើការផ្សព្វផ្សាយ និងការបង្កើតការយល់ដឹង, ខ្លឹមសារដាក់នៅក្នុងថ្នាលឌីជីថល និងការផ្សាយជាសាធារណៈ និងយន្តការផ្តល់ព័ត៌មានផ្សេងៗត្រូវតែគិតគូរឱ្យបានគត់ម្មត់។ ផ្ទាំងរូបភាព, វីដេអូនៃភាពជោគជ័យរបស់សហគ្រាសក្នុងការចាប់យកបច្ចេកវិទ្យាឌីជីថល (Success Stories) និងព័ត៌មានចាំបាច់មួយចំនួនទៀតនឹងត្រូវបានផ្សព្វផ្សាយទូលំទូលាយនៅលើថ្នាល បរិវត្តកម្មឌីជីថលសហគ្រាសដែលបានបង្កើតឡើងនៅក្នុងសកម្មភាពទី៣ និងនៅមជ្ឈមណ្ឌលបរិវត្តកម្មឌីជីថលសហគ្រាស។

## តារាងទី៧៖ សង្ខេបអំពីសកម្មភាពជាអាទិភាពនៃកម្មវិធី

| ល.រ | | បរិយាយ |
|---|---|---|
| សកម្មភាពទី១ | ការលើកកម្ពស់ឌីជីថលូបនីយកម្ម នៃប្រតិបត្តិការធុរកិច្ច និង យុទ្ធសាស្ត្រទីផ្សាររបស់សហគ្រាស | • ការវាយតម្លៃកម្រិតត្រៀមខ្លួនចាប់យកឌីជីថលរបស់សហគ្រាស<br>• ការរៀបចំផែនទីចង្អុលផ្លូវស្តីពីដំណោះស្រាយឌីជីថល<br>• ការរៀបចំផែនទីចង្អុលផ្លូវស្តីពីការបណ្តុះបណ្តាលបច្ចេកវិទ្យាឌីជីថល |
| សកម្មភាពទី២ | ការស្រាវជ្រាវ និង រៀបចំផែនការបរិវត្តកម្មឌីជីថលសហគ្រាសតាមវិស័យ | • សិក្សាស្រាវជ្រាវជាប្រចាំទៅលើតម្រូវការឧបករណ៍ឌីជីថល (digital tool) និងការវិវត្តថ្មីៗនៃបច្ចេកវិទ្យាឌីជីថលដែលសហគ្រាសត្រូវការ<br>• រៀបចំ និងធ្វើបច្ចុប្បន្នភាពកម្រងសំនួរក្នុងការវាយតម្លៃការត្រៀមខ្លួនរបស់សហគ្រាសក្នុងការចាប់យកឌីជីថល |
| សកម្មភាពទី៣ | ការអភិវឌ្ឍថ្នាលបរិវត្តកម្មឌីជីថលសហគ្រាស | • កន្លែងប្រមូលផ្តុំមួយ (One Stop Shop) និងជាកន្លែងផ្គូផ្គងរវៀងអ្នកផ្តល់ និងអ្នកត្រូវការដំណោះស្រាយឌីជីថលទៅតាមកម្រិតត្រៀមខ្លួន<br>• ស្វែងរកដំណោះស្រាយឌីជីថល និង ក្រុមហ៊ុនផ្តល់សេវាកម្ម ឌីជីថលដែលមានគុណវុឌ្ឍិគ្រប់គ្រាន់តាមរយៈយន្តការ Pre-approved solution<br>• វាយតម្លៃកម្រិតត្រៀមខ្លួនក្នុងការចាប់យកឌីជីថលរបស់សហគ្រាស (Digital Readiness Assessment) តាមរយៈអនឡាញ<br>• សកម្មភាពស្នូលក្នុងចំណោមសកម្មភាពទាំង៥ នៃកម្មវិធីទាំងមូល<br>• ឯកសារ, អត្ថបទ, ការពណ៌នាជារូប និងវីដេអូខ្លីៗជាដើម |
| សកម្មភាពទី៤ | ការបង្កើតមជ្ឈមណ្ឌលបរិវត្តកម្មឌីជីថលសហគ្រាស | • ទីតាំងរូបវន្តសម្រាប់ផ្តល់ព័ត៌មាន (Help Desk Service), ប្រើប្រាស់ថ្នាលឌីជីថលនិងផ្តល់ប្រឹក្សាយោបល់ដល់សហគ្រាសដែលមានបំណងធ្វើបរិវត្តកម្មឌីជីថល<br>• ជួយដល់សហគ្រាសក្នុងការវាយតម្លៃកម្រិតត្រៀមខ្លួនចាប់យកឌីជីថល និងជួយសហគ្រាសកំណត់ប្រភេទផលិតផល ឬ សេវាកម្មដែលជំរុញឌីជីថលូបនីយកម្មតាមរយៈការប្រើប្រាស់ថ្នាលឌីជីថលដែលបានរៀបចំក្នុងសកម្មភាពទី៣<br>• ផ្តល់ព័ត៌មានជូនម្ចាស់សហគ្រាសដែលមានបំណងចាប់ផ្តើមដំណើរការបរិវត្តកម្មឌីជីថល<br>• បណ្តុះបណ្តាលសហគ្រាសក្នុងការចាប់យកឌីជីថល |

| | | |
|---|---|---|
| សកម្មភាពទី៥ | ការរៀបចំយុទ្ធការថ្នាក់ជាតិលើការផ្សព្វផ្សាយ និងបង្កើតការយល់ដឹង | • ការរៀបចំយុទ្ធសាស្ត្រផ្សព្វផ្សាយ<br>• ការរៀបចំយុទ្ធនាការថ្នាក់ជាតិលើការផ្សព្វផ្សាយ និងបង្កើតការយល់ដឹង<br>• ខ្លឹមសារដាក់នៅក្នុងថ្នាលឌីជីថល<br>• ផ្ទាំងរូបភាព វីដេអូនៃភាពជោគជ័យរបស់សហគ្រាសក្នុងការចាប់យកបច្ចេកវិទ្យាឌីជីថល<br>• ផ្សព្វផ្សាយលើថ្នាលបរិវត្តកម្មឌីជីថលសហគ្រាស និងនៅមជ្ឈមណ្ឌលបរិវត្តកម្មឌីជីថលសហគ្រាស<br>• យន្តការផ្តល់ព័ត៌មានផ្សេងៗ<br>• ការផ្សាយជាសាធារណៈ |

## ៣.៤. ឃ្នាស់ (Enablers)នៃការអនុវត្តកម្មវិធី

### ៣.៤.១. ក្របខណ្ឌគតិយុត្ត និងយន្តការគាំទ្រពីភាគីពាក់ព័ន្ធ

នាពេលកន្លងមក,រាជរដ្ឋាភិបាលបានដាក់ចេញនូវក្របខណ្ឌច្បាប់,ក្របខណ្ឌគោលនយោបាយ, ផែនការយុទ្ធសាស្ត្រ និងការគាំទ្រនានាក្នុងទម្រង់ជាមូលនិធិនិងគ្រឹះស្ថានដើម្បីផ្តល់នូវបរិយាកាសអំណោយផលដល់សហគ្រាសគ្រប់កម្រិតក្នុងការកសាងនិងអភិវឌ្ឍសមត្ថភាពនៅក្នុងសេដ្ឋកិច្ចឌីជីថល។ រាជរដ្ឋាភិបាលបានដាក់ចេញយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤, គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាឆ្នាំ២០១៥-២០២៥, ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ២០១៩-២០២៣, ផែនការមេបច្ចេកវិទ្យាព័ត៌មាន និងគមនាគមន៍កម្ពុជាឆ្នាំ២០២០, យុទ្ធសាស្ត្រសមាហរណកម្មពាណិជ្ជកម្មកម្ពុជាឆ្នាំ២០១៩-២០២៣, ផែនទីបង្ហាញផ្លូវវិទ្យាសាស្ត្របច្ចេកវិទ្យា និងនវានុវត្តន៍កម្ពុជា ២០៣០, គោលនយោបាយអភិវឌ្ឍន៍សហគ្រាសធុនតូច និង មធ្យម, យុទ្ធសាស្ត្រពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក, ក្របខណ្ឌផែនការយុទ្ធសាស្ត្រ និងកម្មវិធីស្តារ និងជំរុញកំណើនសេដ្ឋកិច្ចកម្ពុជាក្នុងការរស់នៅជាមួយកូវីដ-១៩ តាមគន្លងប្រក្រតីភាពថ្មីសម្រាប់ឆ្នាំ២០២១-២០២៣ និងក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និង សង្គមឌីជីថលកម្ពុជា២០២១-២០៣៥, គោលនយោបាយរដ្ឋាភិបាលឌីជីថល ២០២២-២០៣៥ និងជាពិសេសច្បាប់ស្តីពីការវិនិយោគនៃព្រះរាជាណាចក្រកម្ពុជាដើម្បីបង្កភាពងាយស្រួល និងបង្កើតបរិយាកាសអំណោយផលដល់ការធ្វើអាជីវកម្ម និងវិនិយោគនៅកម្ពុជា។ បន្ថែមលើនេះ, ដើម្បីគាំទ្រដល់កំណើននៃវិស័យពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក, លិខិតបទដ្ឋានចាំបាច់មួយចំនួនត្រូវបានដាក់ចេញជាបន្តបន្ទាប់ដើម្បីគាំទ្រដល់ការអនុវត្តច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ព្រមទាំងច្បាប់ស្តីពីកិច្ចការពារអ្នកប្រើប្រាស់ផងដែរ។

បន្ថែមលើក្របខណ្ឌគតិយុត្តខាងលើដែលគាំទ្រដល់ការលើកកម្ពស់ការអភិវឌ្ឍសមត្ថភាពឌីជីថលរបស់សហគ្រាស,ការគាំទ្រហិរញ្ញវត្ថុនិងមិនមែនហិរញ្ញវត្ថុក៏ជាកត្តាជំរុញកម្មវិធីឱ្យជោគជ័យផងដែរ។កន្លងមក,ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានផ្តោតការយកចិត្តទុកដាក់ក្នុងការអភិវឌ្ឍសហគ្រាសដោយបានដាក់ចេញនូវយន្តការគាំទ្រមួយចំនួនដូចខាងក្រោម៖

**រូបភាពទី១៨៖** ការផ្តួចផ្តើមក្នុងការគាំទ្ររបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

**០១**
- មូលនិធិអភិវឌ្ឍន៍ជំនាញ (ឆ្នាំ ២០១៨)

ដើម្បីគាំទ្រដល់ការអភិវឌ្ឍជំនាញ តាមរយៈការកៀរគរធនធាន និងបង្កើនកម្លាំងពលកម្មជំនាញ

**០២**
- អនុក្រឹត្យស្តីពី ការលើកទឹកចិត្តផ្នែកពន្ធដារសម្រាប់សហគ្រាសធុនតូច និងមធ្យម ក្នុងវិស័យអាទិភាពឆ្នាំ ២០១៨)
- មជ្ឈមណ្ឌលបណ្តុះធុរកិច្ចថ្មី "តេជោ" (ឆ្នាំ ២០២០)

ដើម្បីលើកកម្ពស់ការអភិវឌ្ឍធុរកិច្ចថ្មី និងបង្កើនសមត្ថភាពផលិតកម្មក្នុងស្រុក និងបង្កើតការងារ

**០៣**
- គម្រោងវិនិយោគរួម (ឆ្នាំ ២០១៨)

ដើម្បីអនុញ្ញាតឱ្យក្រុមហ៊ុនគ្រប់គ្រងមូលធនបង្កើតគម្រោងវិនិយោគ ប្រមូលដើមទុនពីអ្នកវិនិយោគ ដើម្បីវិនិយោគលើគម្រោងដែលមានភាពជាក់លាក់

**០៤**
- មូលនិធិអភិវឌ្ឍន៍សហគ្រិនភាព (ឆ្នាំ ២០១៩)
- សហគ្រិនខ្មែរ (ឆ្នាំ ២០១៩)

ដើម្បីគាំទ្រដល់ការធ្វើពិពិធកម្មសេដ្ឋកិច្ច នវានុវត្តន៍ និងការបង្កើតការងារសមរម្យ

**០៥**
- ធនាគារសហគ្រាសធុនតូច និងមធ្យម កម្ពុជា ម.ក (ឆ្នាំ ២០២០)
- សាជីវកម្មធានាឥណទានកម្ពុជា (ឆ្នាំ ២០២០)

ដើម្បីបង្កើនលទ្ធភាពទទួលបានហិរញ្ញប្បទាន ជាមួយនឹងលក្ខខណ្ឌអនុគ្រោះ សម្រាប់សហគ្រាសធុនតូចនិងមធ្យមកម្ពុជា ដើម្បីកំណើនសេដ្ឋកិច្ច



បន្ថែមលើការគាំទ្ររបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ, ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និង នវានុវត្តន៍ក៏បានបង្កើតគេហទំព័រ KhmerSME ដើម្បីផ្តល់ព័ត៌មាន និងការគាំទ្រដល់សហគ្រាសធុនតូចនិងមធ្យម, ក្រសួងពាណិជ្ជកម្មក៏បានបង្កើតផ្សារខេមបូខាត្រេដនៃគម្រោងអភិវឌ្ឍន៍វិស័យពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនៅកម្ពុជា (Go4eCAM), វិទ្យាស្ថានជាតិសហគ្រិនភាព និងនវានុវត្តន៍នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងការគាំទ្រមួយចំនួនទៀតពីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍។ ក្រៅពីស្ថាប័នរាជរដ្ឋាភិបាលក៏មានដៃគូអភិវឌ្ឍន៍ និងសមាគមមួយចំនួនទៀតដូចជាធនាគារពិភពលោក (World Bank), ធនាគារអភិវឌ្ឍន៍អាស៊ី (ADB), កិច្ចសហប្រតិបត្តិការអាល្លឺម៉ង់ (GIZ), មូលនិធិអន្តរជាតិសម្រាប់អភិវឌ្ឍន៍កសិកម្ម (IFAD) តាមរយៈគម្រោងគាំទ្រនិរន្តរភាព ហេដ្ឋារចនាសម្ព័ន្ធជនបទដើម្បីទីផ្សារកសិករ និងពាណិជ្ជូបណីយកម្មកសិកម្ម (Sustainable Assets for Agriculture Markets, Business and Trade - SAAMBAT), កម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ (UNDP), សមាគមសហគ្រិនវ័យក្មេងកម្ពុជា, សមាគមសហគ្រិនស្ត្រីកម្ពុជា, សហព័ន្ធនិយោជក និងសមាគមពាណិជ្ជកម្មកម្ពុជា, សមាគមសហព័ន្ធហិរញ្ញវត្ថុ និងបច្ចេកវិទ្យាកម្ពុជា, Business Network International (BNI), សម្ព័ន្ធសមាគមសហគ្រាសធុនតូច និងមធ្យមកម្ពុជា (FASMEC), សភាពាណិជ្ជកម្មកម្ពុជា, សភាពាណិជ្ជកម្មអឺរ៉ុបនៅកម្ពុជា, សភាពាណិជ្ជកម្មអង់គ្លេសនៅកម្ពុជា, សភាពាណិជ្ជកម្មអាមេរិកនៅកម្ពុជា និងវិស័យឯកជនជាច្រើនទៀតដែលបានគាំទ្រដល់សហគ្រាសគ្រប់កម្រិតនៅកម្ពុជា។

បរិវត្តកម្មឌីជីថលសហគ្រាសគឺជាផ្នែកមួយដ៏សំខាន់នៃការធ្វើទំនើបកម្មរចនាសម្ព័ន្ធសហគ្រាស និងលើកកម្ពស់ការត្រៀមខ្លួនរបស់សហគ្រាសនៅក្នុងស្រុកក្នុងការចាប់យកនិងការធ្វើសមាហរណកម្មខ្សែច្រវាក់ផលិតកម្មទៅក្នុងសេដ្ឋកិច្ចឌីជីថលនៅក្នុងប្រទេស តំបន់ និងសកល។ ក្នុងន័យនេះ, ការគាំទ្រពីគ្រប់ភាគីពាក់ព័ន្ធដើម្បីជំរុញ ការងារនេះជាការងារចាំបាច់ ហើយនៅក្នុងថ្នាលបរិវត្តកម្មឌីជីថលសហគ្រាសដែលបានរៀបចំឡើងក៏បានប្រមូលផ្តុំការគាំទ្រ (Available Support) ដែលគាំទ្រទាំងផ្នែកហិរញ្ញវត្ថុ (Financial Support) និងមិនមែនហិរញ្ញវត្ថុ (Non-Financial Support) ដើម្បីសម្រួលដល់សហគ្រាសក្នុងការទទួលបានព័ត៌មានច្រើន។បន្ថែមលើនេះ,មជ្ឈមណ្ឌលបរិវត្តកម្មឌីជីថលសហគ្រាស (Enterprises Go Digital Hub) នឹងកៀរគរការចូលរួមពីវិស័យឯកជន និងដៃគូអភិវឌ្ឍន៍បន្ថែមទៀតដើម្បីបង្កើនកិច្ចសហការក្នុងការធ្វើបរិវត្តកម្មឌីជីថលសហគ្រាស ប្រកបដោយភាពប្រទាក់ក្រឡា និងគ្រប់ជ្រុងជ្រោយពីគ្រប់ភាគីពាក់ព័ន្ធ។

ជារួមយន្តការគាំទ្រទាំងហិរញ្ញវត្ថុ និងមិនមែនហិរញ្ញវត្ថុមានច្រើន ប៉ុន្តែនៅខ្វះយន្តការសម្របសម្រួល ដើម្បីបង្កើនប្រសិទ្ធភាពនៃការគាំទ្រទាំងនោះអោយអស់សក្តានុពល ។ ក្នុងន័យនេះ, ថ្នាលបរិវត្តកម្មឌីជីថលសហគ្រាស និងមជ្ឈមណ្ឌលបរិវត្តកម្មឌីជីថលសហគ្រាស ដែលដាក់ចេញនូវក្នុងសកម្មភាពទី៣ និងទី៤ នៃកម្មវិធីនេះត្រូវខិតខំប្រមូលផ្តុំនូវការគាំទ្រទាំងអស់ដើម្បីផ្តល់ព័ត៌មានសំបូរបែបដល់សហគ្រាស និង ទាញយកប្រយោជន៍ជាអតិបរមាពីក្របខណ្ឌគតិយុត្តនិងយន្តការគាំទ្រដែលមានស្រាប់។

### ៣.៤.២. ហេដ្ឋារចនាសម្ព័ន្ធឌីជីថល

ឃ្នាស់សំខាន់មួយទៀតនៃកម្មវិធីបរិវត្តកម្មឌីជីថលសហគ្រាសនេះគឺហេដ្ឋារចនាសម្ព័ន្ធឌីជីថលដែលគាំទ្រដល់សហគ្រាសក្នុងការអភិវឌ្ឍសមត្ថភាពឌីជីថល។ គិតត្រឹមឆ្នាំ២០២២តាមរបាយការណ៍នៃការតភ្ជាប់ឌីជីថល ការជាវសេវាទូរស័ព្ទមានចំនួន ១៩,៦ លាន, ការជាវសេវាអ៊ីនធឺណែតចល័តមានចំនួន ១៧,៥ លាន, ការជាវសេវាអ៊ីនធឺណិតអចល័តមានចំនួន ៤៨៤ ៣៩៨ លាន, ប្រជាជនដែលអាចតភ្ជាប់អ៊ីនធឺណិតមានចំនួន ១៣,៣លាន, គណនី Facebook មានចំនួន ១២លាន, ខ្សែកាបអុបទិកលើគោកមានប្រវែង ១៩ ២៧៩ គីឡូម៉ែត្រ និង ខ្សែកាបអុបទិកក្រោមបាតសមុទ្រមានប្រវែង ២៣ ៦០០ គីឡូម៉ែត្រ ខណៈដែលចំនួនប្រជាជនសរុបប្រមាណ ១៦,៨៣ លាននាក់។

**រូបភាពទី ១៩៖** ទិន្នន័យនៃស្ថានភាពនៃការតភ្ជាប់ឌីជីថលនៅឆ្នាំ ២០២២




**ប្រភព៖** ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ និងធនាគារពិភពលោក ២០២២

តាមរយៈរបាយការណ៍នៅក្នុងគោលនយោបាយរដ្ឋាភិបាលឌីជីថលកម្ពុជា ២០២២-២០៣៥ ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាននៅតាមក្រសួង-ស្ថាប័នមានសរុបចំនួន១៨២ប្រព័ន្ធដែលក្នុងនោះប្រព័ន្ធដែលកំពុងប្រើប្រាស់មានចំនួន ១៦៧, ឈប់ប្រើប្រាស់មានចំនួន ២, កំពុងអភិវឌ្ឍន៍មានចំនួន ៧ និងកំពុងសាកល្បងមានចំនួន ៦។

**តារាងទី៤៖** ស្ថានភាពនៃប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាននៅតាមក្រសួង-ស្ថាប័ន

| ស្ថានភាព | ចំនួនប្រព័ន្ធ | ភាគរយ |
|---|---|---|
| កំពុងប្រើប្រាស់ | ១៦៧ | ៩១,៧៥% |
| ឈប់ប្រើប្រាស់ | ២ | ១,០៩% |
| កំពុងអភិវឌ្ឍន៍ | ៧ | ៣,៨៤% |
| កំពុងសាកល្បង | ៦ | ៣,២៩% |
| **សរុប** | **១៨២** | **១០០%** |

**ប្រភព៖** គោលនយោបាយរដ្ឋាភិបាលឌីជីថលកម្ពុជា ២០២២-២០៣៥

ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានទាំងនោះត្រូវបានអភិវឌ្ឍន៍ដើម្បីបម្រើដល់ការគ្រប់គ្រងការងាររដ្ឋបាលផ្ទៃក្នុងរបស់ក្រសួង-ស្ថាប័ន, ការគ្រប់គ្រងបុគ្គលិក, ការផ្តល់សេវាសាធារណៈតាមអនឡាញមួយចំនួន, ការទូទាត់ប្រាក់ និងប្រព័ន្ធដែលបម្រើដល់សកម្មភាពធុរកិច្ច និងសេដ្ឋកិច្ចឌីជីថលមួយចំនួនផងដែរ។

**រូបភាពទី២០៖** សម្រង់នៃប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានមួយចំនួននៅតាមបណ្តាក្រសួង-ស្ថាប័ន




ក្រៅពីប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានខាងលើវិស័យឯកជនមួយចំនួនក៏បានរៀបចំនូវប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានមួយចំនួនដើម្បីផ្តល់ជាដំណោះស្រាយឌីជីថលដែលបម្រើដល់សកម្មភាពអាជីវកម្ម និង ធុរកិច្ច។

**រូបភាពទី២១៖** សម្រង់នៃប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានមួយចំនួននៃវិស័យឯកជន



បើពិនិត្យទៅលើប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានឬថ្នាលឌីជីថលដែលរៀបចំនិងអភិវឌ្ឍន៍ដោយវិស័យឯកជនខាងលើ ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានឬថ្នាលឌីជីថលទាំងនោះភាគច្រើនផ្តោតតែទៅលើការផ្តល់ព័ត៌មានអំពីរបៀបនៃការប្រកបអាជីវកម្មអនឡាញ។ ដោយឡែក, ក្រុមហ៊ុន Banhji និង KiU បានផ្តល់ជាដំណោះស្រាយឌីជីថលមួយចំនួនជូនដល់សហគ្រាសក្នុងការចាប់យកការប្រើប្រាស់បច្ចេកវិទ្យាឌីជីថល ប៉ុន្តែដោយសារក្រុមហ៊ុនទាំងពីរជាក្រុមហ៊ុនឯកជន, សហគ្រាសមួយចំនួនមិនមានលទ្ធភាពគ្រប់គ្រាន់ក្នុងការប្រើប្រាស់ផលិតផល ឬសេវាកម្មឌីជីថលរបស់ក្រុមហ៊ុន និងមានភាពស្ទាក់ស្ទើរក្នុងការប្រើប្រាស់ពេញលេញសម្រាប់ប្រតិបត្តិការអាជីវកម្មរបស់ខ្លួន។ បន្ថែមលើនេះ, ដំណោះស្រាយឌីជីថលរបស់ក្រុមហ៊ុនឯកជនទាំងនោះនៅមានកម្រិត និងខ្លះទៀតមិនអាចផ្តល់ដំណោះស្រាយតាមការចង់បានរបស់សហគ្រាសហើយខ្លះទៀតមិនអាចធានាបាននូវសុវត្ថិភាពទិន្នន័យនិងបញ្ហាសន្តិសុខឌីជីថលដែលធ្វើអោយការធ្វើបរិវត្តកម្មឌីជីថលសហគ្រាសនៅមានកម្រិតទាបបើធៀបនឹងប្រទេសឈានមុខដូចជាសិង្ហបុរី។

ជារួម, កម្ពុជាពុំទាន់មានថ្នាលឌីជីថលដែលប្រមូលផ្តុំនូវដំណោះស្រាយឌីជីថលដែលបង្កើតឡើងដោយវិស័យសាធារណៈដូចបានរៀបរាប់ខាងលើ និងដំណោះស្រាយឌីជីថលដែលបង្កើតឡើងដោយវិស័យឯកជននៅឡើយ។ ក្នុងន័យនេះ, ថ្នាលបរិវត្តកម្មឌីជីថលសហគ្រាស (Enterprises Go Digital Platform) ដែលបង្កើតនៅក្នុងសកម្មភាពទី៣នៃកម្មវិធីនឹងដើរតួបំពេញចន្លោះនេះ។ លើសពីនេះទៀត, ថ្នាលនេះនឹងផ្តល់ជាអនុសាសន៍ (Recommendation) ជូនសហគ្រាសក្នុងការសម្រេចចិត្តប្រើប្រាស់ដំណោះស្រាយឌីជីថលដែលអាចជឿទុកចិត្តបានតាមរយៈយន្តការនៃការពិនិត្យទៅលើលក្ខណៈសម្បត្តិនៃប្រភេទផលិតផល/សេវាកម្មឌីជីថល (Pre-Approved Solutions) ដែលមាននៅលើទីផ្សារពីអ្នកជំនាញ ដើម្បីបង្កើនទំនុកចិត្តដល់សហគ្រាស។

### ៣.៤.៣. ទេពកោសល្យសម្រាប់សេដ្ឋកិច្ចឌីជីថល

**រូបភាពទី២២៖** ស្ថានភាពអក្ខរកម្មឌីជីថលកម្ពុជា




**ប្រភព៖** Digital Literacy for Employability and Entrepreneurship among Cambodia Youth , 2020

ធនធានមនុស្សដែលមានទេព្យកោសល្យឌីជីថល គឺជាតួអង្គដ៏សំខាន់នៅក្នុងបរិការណ៍នៃបរិវត្តកម្មឌីជីថលដែលចូលរួមធានាបាននូវការបង្កើតថ្មី និងនវានុវត្តន៍ រាប់ទាំងការបង្កើតធុរកិច្ចថ្មីៗ, ការដោះស្រាយបញ្ហាបានឆាប់រហ័សក្នុងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងការការពារសុវត្ថិភាពនៃប្រព័ន្ធទាំងមូល។ការផ្លាស់ប្តូរទៅរកភាពជាអ្នកដឹកនាំឌីជីថលដែលឆ្លើយតបទៅនឹងការវិវឌ្ឍយ៉ាងឆាប់រហ័សនៃបច្ចេកវិទ្យាព័ត៌មានចាំបាច់ត្រូវការនូវកិច្ចខិតខំរយៈពេលវែងក្នុងការអភិវឌ្ឍអ្នកដឹកនាំឌីជីថល និងការកសាងភាពជាអ្នកដឹកនាំឌីជីថល។ ផ្អែកលើស្ថានភាពនៃអក្ខរកម្មឌីជីថលខាងលើ, រាជរដ្ឋាភិបាលត្រូវបង្កើនកិច្ចខិតខំប្រឹងប្រែងក្នុងការបណ្តុះទេពកោស្យសម្រាប់សេដ្ឋកិច្ចឌីជីថលទាំងជំនាញឌីជីថល និងជំនាញពាក់ព័ន្ធហើយការដាក់ចេញនូវផែនទីចង្អុលផ្លូវសម្រាប់ការបណ្តុះបណ្តាលទៅដល់សហគ្រាសដូចបានកំណត់ក្នុងសកម្មភាពទី១ និងតាមរយៈមជ្ឈមណ្ឌលបរិវត្តកម្មឌីជីថលក្នុងសកម្មភាពទី៤ នឹងជួយក្នុងការកសាងទេពកោសល្យសម្រាប់សេដ្ឋកិច្ចឌីជីថល។

## ៣.៥. វិសាលភាព

កម្មវិធីបរិវត្តកម្មឌីជីថលសហគ្រាសនឹងចាប់ផ្តើមពីកម្រិតមូលដ្ឋាននៃការជំរុញការចាប់យកបច្ចេកវិទ្យាឌីជីថលរបស់សហគ្រាសទៅក្នុងសកម្មភាពអាជីវកម្មដើម្បីពង្រឹងភាពធន់របស់សហគ្រាសទៅនឹងវិបត្តិ និងផ្តោតទៅលើវិស័យអាទិភាពដែលជាប្រភពនៃកំណើនសេដ្ឋកិច្ចជាតិជាមុន។នៅពេលដែលកម្រិតនៃការចាប់យកបច្ចេកវិទ្យាឌីជីថលក្នុងកម្រិតមូលដ្ឋានទទួលបានលទ្ធផលគួរឱ្យកត់សម្គាល់ពីការអនុវត្តកម្មវិធីក្នុងរយៈពេលកំណត់មួយ, កម្មវិធីនឹងពង្រីកវិសាលភាពអនុវត្តទៅកម្រិតមធ្យម និងកម្រិតខ្ពស់បន្ថែមទៀតដើម្បីផ្តល់បរិយាកាសអំណោយផលដល់សហគ្រាសអាចផ្លាក់ទៅនឹងខ្សែច្រវាក់តម្លៃឌីជីថលតំបន់និងសកលសំដៅធ្វើបរិវត្តកម្មឌីជីថលសហគ្រាសនៅក្នុងគ្រប់វិស័យនិងគ្រប់ទំហំនៃសហគ្រាស រួមទាំងធុរកិច្ចថ្មី ដែលយន្តការនេះគឺអនុវត្តតាមគោលការណ៍ផ្តួចផ្តើម និងពង្រីកដើម្បីប្រសិទ្ធភាព (Land and Expand for Efficiency) នៅក្នុងក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ចនិងសង្គមឌីជីថលកម្ពុជា២០២១-២០៣៥។ លើសពីនេះទៀត, កម្មវិធីនឹងពង្រីកវិសាលភាពទីតាំងនៃមជ្ឈមណ្ឌលបរិវត្តកម្មឌីជីថលសហគ្រាសដែលមានការិយាល័យកណ្តាល (Head Quarter) មួយនៅរាជធានីភ្នំពេញទៅខេត្តសក្តានុពលណាមួយដែលមានសកម្មភាពសេដ្ឋកិច្ចនិងធុរកិច្ចច្រើនបន្ថែមទៀតចាប់ពីឆ្នាំ២០២៥តទៅ។

## ៣.៦. ចីរភាពនៃកម្មវិធី

ទោះបីជាមានការគាំទ្រយ៉ាងពេញទំហឹងពីថ្នាក់ដឹកនាំក៏ដោយ អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការសេដ្ឋកិច្ច និងធុរកិច្ចឌីជីថលដែលទទួលបន្ទុកដឹកនាំ និងសម្របសម្រួលកម្មវិធីនេះនឹងសិក្សាបន្ថែមទៅលើគំរូធុរកិច្ច (Business Model) ឬគម្រោងអាជីវកម្ម (Business Plan) ដែលអាចបង្កើតជាប្រភពចំណូលទ្រទ្រង់ដល់ដំណើរការនៃកម្មវិធី និងរក្សាបាននូវចីរភាពនៃកម្មវិធីនាពេលខាងមុខបន្ទាប់ពីមានការវាយតម្លៃកម្មវិធីក្នុងរយៈពេលកំណត់មួយ និងបន្ទាប់ពីទទួលបានសមិទ្ធផលដែលអាចវាស់វែងបានពីការចាប់យកបច្ចេកវិទ្យាឌីជីថល ទៅប្រើប្រាស់នៅក្នុងប្រតិបត្តិការអាជីវកម្មរបស់សហគ្រាសជាពិសេសសហគ្រាសធុនតូច និងមធ្យម។

# ៤

# យន្តការដឹកនាំ សម្របសម្រួល និង អនុវត្តកម្មវិធី

## ៤. យន្តការដឹកនាំ សម្របសម្រួល និង អនុវត្តកម្មវិធី

### ៤.១. ស្ថាប័នដឹកនាំ សម្របសម្រួល និង អនុវត្តកម្មវិធី

គិតចាប់ពីខែមករា ឆ្នាំ២០២៣ តទៅ កម្មវិធីបរិវត្តកម្មឌីជីថលសហគ្រាស ដែលបានរៀបចំឡើងនេះ នឹងស្ថិតក្រោមការដឹកនាំ និង សម្របសម្រួលដោយគណៈកម្មាធិការសេដ្ឋកិច្ច និង ធុរកិច្ចឌីជីថល(គ.ស.ធ.ឌ.)ដោយមានអគ្គលេខាធិការដ្ឋានគ.ស.ធ.ឌ. ជាសេនាធិការបច្ចេកទេស និងអនុវត្តដោយមជ្ឈមណ្ឌលបណ្ដុះធុរកិច្ចថ្មី "តេជោ" តាមរយៈការសហការជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ ដូចបានដាក់ចេញនៅក្នុងវិធាន ការគោលនយោបាយគន្លឹះក្នុងក្របខណ្ឌយុទ្ធសាស្ត្រ និងកម្មវិធីស្តារ និងជំរុញកំណើនសេដ្ឋកិច្ចកម្ពុជាក្នុងការរស់នៅជាមួយកូវីដ-១៩ តាមគន្លងប្រក្រតីភាពថ្មី សម្រាប់ឆ្នាំ២០២១-២០២៣។

**តារាងទី៥៖** ផែនការអនុវត្ត

| ល.រ | សកម្មភាព | ២០២២ | ២០២៣ | | ២០២៤ | | ២០២៥ | | ២០២៦ | | ២០២៧ | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | ឆ១ | ឆ២ | ឆ១ | ឆ២ | ឆ១ | ឆ២ | ឆ១ | ឆ២ | ឆ១ | ឆ២ |
| ១ | ការលើកកម្ពស់ឌីជីថលូបនីយកម្មនៃប្រតិបត្តិការធុរកិច្ច និងយុទ្ធសាស្ត្រទីផ្សាររបស់សហគ្រាស | | x | x | x | x | x | x | x | x | x | x |
| ២ | ការស្រាវជ្រាវ និងរៀបចំផែនការបរិវត្តកម្មឌីជីថលសហគ្រាសតាមវិស័យ | | x | x | x | x | x | x | x | x | x | x |
| ៣ | ការអភិវឌ្ឍថ្នាលបរិវត្តកម្មឌីជីថលសហគ្រាស | x | x | x | x | x | x | x | x | x | x | x |
| ៤ | ការបង្កើតមជ្ឈមណ្ឌលបរិវត្តកម្មឌីជីថលសហគ្រាស | x | x | x | x | x | x | x | x | x | x | x |
| | នៅភ្នំពេញ (ការិយាល័យកណ្ដាល HQ) | x | x | x | x | x | x | x | x | x | x | x |
| | ពង្រីកវិសាលភាពទៅខេត្តសក្តានុពលនៃប៉ូលសេដ្ឋកិច្ចសំខាន់ៗ | | | | | | x | x | x | x | x | x |
| ៥ | ការរៀបចំយុទ្ធនាការថ្នាក់ជាតិលើការផ្សព្វផ្សាយ និងការបង្កើនការយល់ដឹង | x | x | x | x | x | x | x | x | x | x | x |

### ៤.២. ការត្រួតពិនិត្យតាមដាន និងការវាយតម្លៃ

នៅក្នុងផ្នែកនេះនឹងលម្អិតអំពីផែនការសម្រាប់ការត្រួតពិនិត្យតាមដាន និងវាយតម្លៃកម្មវិធីទាំងនៅក្នុងកំឡុងពេលអនុវត្ត និងនៅពេលបញ្ចប់ និងកំណត់អំពីហានិភ័យដែលអាចរាំងស្ទះដល់ការសម្រេចលទ្ធផលនៃកម្មវិធីតាមការរំពឹងទុក។ លទ្ធផលរំពឹងទុក, ការកំណត់សូចនាករជាក់លាក់ដែលអាចវាស់វែងបាន,យន្តការនៃការផ្ទៀងផ្ទាត់លទ្ធផលនិងការសន្មត់ពីហានិភ័យនឹងមានបញ្ជាក់នៅក្នុងតារាងខាងក្រោម៖

**តារាងទី៦៖** ក្របខណ្ឌលទ្ធផលរំពឹងទុកនៃកម្មវិធីបរិវត្តកម្មឌីជីថលសហគ្រាស

<table>
<tr><th colspan="4">ក្របខណ្ឌលទ្ធផលរំពឹងទុកនៃកម្មវិធីបរិវត្តកម្មឌីជីថលសហគ្រាស<br>Enterprises Go Digital Program Result Framework</th></tr>
<tr><td colspan="4">បច្ច័យនៃកម្មវិធីគឺស្របទៅនឹង (Aligned with) វិធានការគោលនយោបាយគន្លឹះជាអាទិភាព "បរិវត្តកម្មសហគ្រាស" នៃសសរស្តម្ភ "ធុរកិច្ចឌីជីថល" នៅក្នុងក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថល២០២១-២០៣៥ និងវិធានការគោលនយោបាយគន្លឹះស្តីពី "ការពង្រឹងភាពធន់ប្រកបដោយចីរភាព និងបរិយាបន្ន" នៃក្របខណ្ឌយុទ្ធសាស្ត្រ និងកម្មវិធីស្តារ និងជំរុញកំណើនសេដ្ឋកិច្ចកម្ពុជាក្នុងការរស់នៅជាមួយកូវីដ-១៩តាមគន្លងប្រក្រតីភាពថ្មីសម្រាប់ឆ្នាំ២០២១-២០២៣" ។</td></tr>
<tr><th>លទ្ធផលរំពឹងទុក<br>Result Chain</th><th>សូចនាករ<br>Indicator</th><th>យន្តការផ្ទៀងផ្ទាត់<br>Mean of Verification</th><th>ការសន្មត់ពីហានិភ័យ<br>Risk Assumption</th></tr>
<tr><td>លទ្ធផលចុងក្រោយនៃកម្មវិធី (Outcome)៖<br>ពង្រឹងសមត្ថភាពឌីជីថលរបស់សហគ្រាស តាមរយៈការធ្វើបរិវត្តកម្មឌីជីថលសហគ្រាស ដើម្បីជំរុញឱ្យសហគ្រាសគ្រប់កម្រិតអាចក្លាយជាភ្នាក់ងារដ៏សកម្មនៅក្នុងសេដ្ឋកិច្ច និងធុរកិច្ចឌីជីថល</td><td>សហគ្រាសគ្រប់ទំហំចំនួន ៤,០០០ នឹងទទួលបានការបណ្តុះបណ្តាលសមត្ថភាពបរិវត្តកម្មឌីជីថលសហគ្រាស ដោយក្នុងនោះមានសហគ្រិនស្ត្រីមិនតិចជាង២៥%</td><td>របាយការណ៍បូកសរុបបញ្ចប់កម្មវិធី</td><td>ការវិវត្តយ៉ាងឆាប់រហ័សនៃបច្ចេកវិទ្យាឌីជីថល ឬបច្ចេកវិទ្យាឌីជីថលដែលពាក់ព័ន្ធមិនបានដំណើរការតាមការរំពឹងទុក</td></tr>
<tr><td>លទ្ធផលរំពឹងទុកទី១៖<br>បង្កើនការផ្តល់ផលិតផល/សេវាកម្មឌីជីថលប្រកបដោយគុណភាពតាមវិស័យនៅលើថ្នាលបរិវត្តកម្មឌីជីថសហគ្រាស</td><td>• ចំនួន ផលិតផល/សេវាកម្មឌីជីថលដែលបានអនុញ្ញាត (Pre-approved solutions) នៅលើ Enterprises Go Digital Platform មានការកើនឡើងក្នុងនោះមានផលិតផល/សេវាកម្ម ឌីជីថលដែលបង្កើតដោយស្ត្រីមានយ៉ាងតិច២៥%</td><td>របាយការណ៍វឌ្ឍនភាព</td><td>ចំនួនដំណោះស្រាយឌីជីថលក្នុងស្រុកមានតិច (Low number of pre-approved solution) មិនអាចផ្គត់ផ្គង់តម្រូវការ</td></tr>
<tr><td>លទ្ធផលរំពឹងទុកទី២៖<br>លើកកម្ពស់លទ្ធភាពទទួលបានព័ត៌មាន, បង្កើនការយល់ដឹងអំពីបរិវត្តកម្មឌីជីថល និង ការបណ្តុះបណ្តាលដល់សហគ្រាស</td><td>• ចំនួនសហគ្រាសដែលមកសាកសួរព័ត៌មាននៅមជ្ឈមណ្ឌលបរិវត្តកម្មឌីជីថលសហគ្រាស មានការកើនឡើងតាមរយៈយុទ្ធនាការផ្សព្វផ្សាយ និងការបង្កើនការយល់ដឹង</td><td>របាយការណ៍វឌ្ឍនភាព</td><td></td></tr>
</table>

| | | | |
|---|---|---|---|
| | • ចំនួនសហគ្រាសដែលចូលវាយតម្លៃកម្រិតត្រៀមខ្លួន (Digital Readiness Assessment) នៅលើ Enterprises Go Digital Portal មានការកើនឡើង<br>• សហគ្រាសនិងអ្នកប្រើប្រាស់ទទួលបានការបណ្ដុះបណ្ដាលពីការប្រើប្រាស់ផលិតផល/សេវាកម្មឌីជីថលមានការកើនឡើង | | |
| **លទ្ធផលរំពឹងទុកទី៣៖**<br>លើកកម្ពស់ការប្រើប្រាស់ថ្នាលឌីជីថលរបស់រាជរដ្ឋាភិបាល | • ចំនួនសហគ្រាសដែលបានចុះបញ្ជីអាជីវកម្មតាមរយៈប្រព័ន្ធចុះបញ្ជីអាជីវកម្មតាមថ្នាលបច្ចេកវិទ្យាព័ត៌មាន (Online Business Registration) ដែលមាននៅលើថ្នាល CamDX មានការកើនឡើង<br>• ចំនួនអ្នកប្រើប្រាស់ថ្នាលសម្គាល់អត្តសញ្ញាណអតិថិជនឌីជីថល (CamDigiKey) និងថ្នាលឌីជីថលផ្សេងៗទៀតមានការកើនឡើង | របាយការណ៍វឌ្ឍនភាព | |

# ៥

# ការបញ្ជ្រាបយេនឌ័រ

## ៥.ការបញ្ជ្រាបយេនឌ័រ

ស្ត្រីបានចូលរួមចំណែកយ៉ាងសំខាន់នៅក្នុងសេដ្ឋកិច្ចកម្ពុជាដោយបានចូលរួមផ្តល់ជាកម្លាំងពលកម្ម និងរួមចំណែកស្មើរគ្រប់វិស័យ ប៉ុន្តែការងារដែលស្ត្រីចូលរួមភាគច្រើនគឺស្ថិតក្នុងវិស័យកាត់ដេរ ពាណិជ្ជកម្ម និងទេសចរណ៍ ខណៈដែលវិស័យផ្សេងទៀតនៅមានកម្រិតនៅឡើយ រួមទាំងវិស័យសាធារណៈ។កន្លងមក,រាជរដ្ឋាភិបាលបានយកចិត្តទុកដាក់ខ្ពស់ក្នុងការដាក់ចេញនូវគោលនយោបាយជាច្រើនដើម្បីបង្កើនការយល់ដឹងពីសមភាពយេនឌ័រ និងមានគម្រោងជាច្រើនរបស់ដៃគូអភិវឌ្ឍន៍ក៏បានកំណត់នូវផែនការសកម្មភាពបញ្ជ្រាបយេនឌ័រ(Gender Mainstreaming Action Plan) ផងដែរ។ កម្មវិធីបរិវត្តកម្មសហគ្រាសឌីជីថលនេះនឹងរៀបចំជាផែនការសកម្មភាពនៃការបញ្ជ្រាបយេនឌ័រនៅគ្រប់សកម្មភាពដែលត្រូវអនុវត្តនិងរៀបចំជារបាយការណ៍ពីចំនួនស្ត្រីដែលទទួលបានផលប្រយោជន៍ពីការអនុវត្តកម្មវិធីនេះ។ ព័ត៌មានស្តីពីការបញ្ជ្រាបយេនឌ័រនឹងរំលេចនៅក្នុងក្របខណ្ឌលទ្ធផលរំពឹងទុក ។

# ៦

# ការគ្រប់គ្រងហានិភ័យ

## ៦.ការគ្រប់គ្រងហានិភ័យ

តាមរយៈការវិវត្តយ៉ាងឆាប់រហ័សនៃបច្ចេកវិទ្យាឌីជីថលកត្តាហានិភ័យចម្បងចំនួនពីរដែលអាចបន្ថយបង្អាក់ដល់ការអនុវត្តកម្មវិធីបរិវត្តកម្មឌីជីថលសហគ្រាសឱ្យសម្រេចតាមលទ្ធផលរំពឹងទុក។ ហានិភ័យទី១ គឺការវិវត្តឥតឈប់ឈរនៃបច្ចេកវិទ្យាឌីជីថលថ្មីៗ នៅក្នុងទីផ្សារ និងសម្រាប់ការប្រើប្រាស់របស់សហគ្រាសអាចធ្វើឱ្យបច្ចេកវិទ្យាដែលពាក់ព័ន្ធ និងបានដាក់ចេញក្នុងកម្មវិធីបរិវត្តកម្មឌីជីថលសហគ្រាសមិនបានដំណើរការតាមការរំពឹងទុក។ការណ៍នេះអាចធ្វើឱ្យសហគ្រាសដែលបានចាប់យកបច្ចេកវិទ្យាឌីជីថលរួចហើយ មានភាពលំបាកក្នុងការបត់បែន សម្របតាមទីផ្សារ និងជាពិសេសបង្កើនប្រសិទ្ធភាពក្នុងប្រតិបត្តិការរបស់ខ្លួន។ ចំណែកហានិភ័យទី២ គឺ ចំនួនដំណោះស្រាយឌីជីថលផ្គត់ផ្គង់ដោយអ្នកផ្តល់ផលិតផលសេវាកម្មឌីជីថលមានតិច ឬ មិនគ្រប់គ្រាន់សម្រាប់បំពេញតម្រូវការចាប់យកឌីជីថលក្នុងទីផ្សារ។ដូច្នេះមានវិធានការមួយចំនួនដែលបានគិតគូរដើម្បីគ្រប់គ្រងនិងបញ្ចៀសហានិភ័យដែលអាចជាឧបសគ្គរាំងស្ទះក្នុងការអនុវត្តកម្មវិធីប្រកបដោយប្រសិទ្ធភាព និងចីរភាព។ ការសិក្សាស៊ីជម្រៅនៃនិន្នាការបច្ចេកវិទ្យាឌីជីថលថ្មីៗក្នុងស្រុក គួរធ្វើឡើងជាប្រចាំដើម្បីធានាបានបច្ចុប្បន្នភាពនិងភាពពាក់ព័ន្ធនៃដំណោះស្រាយបច្ចេកវិទ្យា សម្រាប់សហគ្រាស។ បន្ថែមលើនេះការបណ្តុះបណ្តាល និងកិច្ចសហការជាមួយភាគីពាក់ព័ន្ធលើការពង្រឹងសមត្ថភាពក្នុងការអភិវឌ្ឍ និងផលិតដំណោះស្រាយឌីជីថលរបស់អ្នកផ្តល់សេវាកម្មឌីជីថល នឹងមានភាពចាំបាច់ ដើម្បីធានាបានសេវាកម្មប្រកបដោយស្តង់ដារនិងគុណភាពសមស្របសម្រាប់ទីផ្សារ។លើសពីនេះទៀត,ក្នុងសកម្មភាពទី៣នៃកម្មវិធីបរិវត្តកម្មឌីជីថលនឹងបង្កើតដំណោះស្រាយឌីជីថលមួយចំនួនដើម្បីបម្រើដល់ប្រតិបត្តិការប្រចាំថ្ងៃរបស់ធុរកិច្ច និងសហគ្រាសដូចជាការគ្រប់គ្រងបញ្ជីគណនេយ្យ, ការគ្រប់គ្រងធនធានមនុស្ស, ការគ្រប់គ្រងសារពើភណ្ឌ, ការគ្រប់គ្រងធនធានមនុស្ស, ការគ្រប់គ្រងប្រព័ន្ធបើកប្រាក់បៀវត្ស និងដំណោះស្រាយមួយចំនួនទៀតដែលអាចជួយបំពេញបន្ថែមដល់តម្រូវការរបស់សហគ្រាស។

# ៧

# សេចក្ដីសន្និដ្ឋាន

## ៧.សេចក្តីសន្និដ្ឋាន

ការដាក់ឱ្យអនុវត្តនូវកម្មវិធីបរិវត្តកម្មឌីជីថលសហគ្រាសរំពឹងថានឹងអាចជួយដល់ការអភិវឌ្ឍសមត្ថភាពឌីជីថលរបស់សហគ្រាសដូចបានកំណត់ក្នុងក្របខណ្ឌយុទ្ធសាស្ត្រ និង កម្មវិធីស្តារ និងជំរុញកំណើនសេដ្ឋកិច្ចកម្ពុជាក្នុងការរស់នៅជាមួយកូវីដ-១៩ តាមគន្លងប្រក្រតីភាពថ្មីសម្រាប់ឆ្នាំ ២០២១-២០២៣ និងជួយជំរុញការអនុវត្តវិធានការគោលនយោបាយនៃក្របខណ្ឌគោល-នយោបាយសេដ្ឋកិច្ច និង សង្គមឌីជីថល ២០២១-២០៣៥ ឱ្យសម្រេចនូវគោលដៅ ១) ការធ្វើទំនើបកម្មរចនាសម្ព័ន្ធសហគ្រាស និង ២) ការលើកកម្ពស់ការត្រៀមខ្លួនរបស់សហគ្រាសនៅក្នុងស្រុកក្នុងការចាប់យក និងការធ្វើសមាហរណកម្មខ្សែច្រវាក់ផលិតកម្មទៅក្នុងសេដ្ឋកិច្ចឌីជីថលនៅក្នុងប្រទេស តំបន់និងសកល។ បើទោះជាកម្មវិធីបានរៀបចំឡើងដោយកំណត់នូវសកម្មភាពជាក់លាក់, លទ្ធផលរំពឹងទុកច្បាស់លាស់ និងការគ្រប់គ្រងហានិភ័យដែលអាចកើតមាន ប៉ុន្តែកម្មវិធីនេះទាមទារឱ្យមានការសម្របសម្រួល និងការចូលរួមគាំទ្រពីគ្រប់ភាគីពាក់ព័ន្ធដើម្បីជំរុញការលើកទឹកចិត្តសហគ្រាសឱ្យចាប់យកការប្រើប្រាស់បច្ចេកវិទ្យាឌីជីថល និង ចូលរួមបង្កើតនូវបរិយាកាសអំណោយផលនានាជូនដល់សហគ្រាសដើម្បីទាញយកអត្ថប្រយោជន៍ពីបច្ចេកវិទ្យាឌីជីថល និងការគាំទ្ររបស់រាជរដ្ឋាភិបាល, វិស័យឯកជន និងដៃគូអភិវឌ្ឍន៍អោយអស់សក្តានុពល និងប្រកបដោយភាពបត់បែនខ្ពស់៕

(+855) 87 888 608
digitaleconomy@mef.gov.kh
www.digitaleconomy.gov.kh

អគារមជ្ឈមណ្ឌលអភិវឌ្ឍធុរកិច្ច (BDC), ជាន់ទី១៧, មហាវិថី OCIC,
សង្កាត់ជ្រោយចង្វារ, ខណ្ឌជ្រោយចង្វារ, រាជធានីភ្នំពេញ